# ការសំភាសន៍របស់ អ្នកមីង ស្រៀង ស្រ៊ុង

កៈ អ្នកធ្វើការសំភាសន៍ គីម ម៉េង ខៈ អ្នកដែលត្រូវបានគេសំភាសន៍ ស្រៀង ស្រ៊ុង

**<u>ការសង្ខេបរបស់លោកយាយ សុខ ផ្កាបូ</u>**

អ្នកមីង សៀង ស្រ៊ុងគាត់មានអាយុ ៦៧ឆ្នាំ ក្នុងឆ្នាំ ២០១៨អ្នកមីង សៀង ស្រ៊ុងមានភេទស្រីអ្នកមីង សៀង ស្រ៊ុងមានទីលំនៅនាពេលបច្ចុប្បន្ន នៅភូមិស្ទឹងជ្រៅ ខេត្តកណ្តាល។

កៈ

ចឹងជាដំបូងជំរាសួរលោកយាយខ្ញុំបាទមកពីរខាងសាកលវិទ្យាល័យបីបាយយូនៃសហរដ្ឋអាមេរិចហើយមានការអញ្ជើញដើម្បីមានការសំភាសន៍លោកយាយអំពីពង្សប្រវត្តិតតើអ្នកមីងអាយអនុញ្ញាត្តិអោយសំភាសន៍លោកយាយពង្សប្រវត្តិអ្នកមីងបានដែលទេ???

ខៈ ចាសបាន ៕

កៈ

ចឹងថ្ងៃនេះគឺជាថ្ងៃដែលខ្ញុំបានសំភាសន៍អ្នកមីងគឺជាថ្ងៃទី២៤ខែ០៣(មីនា)ឆ្នាំ២០១៨ហើយធ្វើការសំភាសន៍ដោយរូបខ្ញុំបាទឈ្មោះគីមម៉េងហើយនាក់សំភាសន៍អ្នកមីងឈ្មោះអ្នកមីងស្រៀងស្រ៊ុង ចឹងផ្តើមឈ្មោះដំបូងខ្ញុំអាចស្គាល់ឈ្មោះរបស់អ្នកមីងបានដែលរឺទេអ្នកមីង???

ខៈ ចាសបានខ្ញុំឈ្មោះ ស្រៀង ស្រ៊ុង៕

កៈ

ចឹងសំណួរដែលខ្ញុំចង់សួរទៅកាន់អ្នកមីងដំបូងឈ្មោះពេញរបស់អ្នកមីងឈ្មោះពេញមានឈ្មោះអ្វីដែលអ្នកមីង???

ខៈ ចាសគឺឈ្មោះចឹងតែម្តងចាសឪពុករបស់គាត់មានឈ្មោះស្រៀង ហើយនឹងមានឈ្មោះស្រ៊ុង

ហើយគឺគ្មានបានប្តូរទៅណាទៅណីអីទេគឺគ្មាននោះទេហាហាហានៅជំនាន់ពោលពតក៏មិនបានប្តូរហើយមកដល់សម័យលូវក៏មិនបានប្តូរដែលហាហាហាឈ្មោះយ៉ាងមិចគឺដាក់តែចឹងតែបើលកាលនៅពីក្មេងក្មេងគេចេះតែហៅហើយនឹងបានដាក់ងាយហើយបានហៅខ្ញុំថាការជ្រូកចឹងទៅហាសហាហាហាពីព្រោះអីខ្ញុំនឹងទៅមើលគោហាសចឹងគេចេះតែហៅទៅហាសគេចេះតែហៅលេងចឹងទៅ៕

កៈ បាទចឹងអ្នកមីងមានឈ្មោះហៅក្រៅអ្វីបន្ថែមទៀតដែលរឺទេអ្នកមីង???

ខៈ ចាសគឺអត់មាននោះទេចាសមានគឺមានតែមួយនឹងគឺឈ្មោះមួយនឹង៕

កៈ បាទចុះឈ្មោះពីក្មេងមានដែលទេអ្នកមីង???

ខ៖ ចាសគឺអត់មាននោះទេ។

ក៖ បាទចឹងអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយអ្នកមីងនៅឆ្នាំនឹង???

ខ៖ ចាសខ្ញុំចូលឆ្នាំថ្មីនឹងខ្ញុំមានអាយុ ៦៧ ឆ្នាំហើយចាស៕

ក៖
បាទហើយអ្នកមីងកើតនៅឆ្នាំណាហើយនឹងខែណាហើយនឹងថ្ងៃណាដែលទៅអ្នកមីង???

ខ៖
ចាសខ្ញុំដូចជាមិនសូវជាចាំនោះទេកូនអើយកាល់ពីមុខវាចេះខ្ញុំវាវាល់ថាយើងនឹងវានឿនហាត់ពេកចឹងហាសខ្ញុំមានបងប្អូនប្រុសប្រុសក៏ប៉ុនតែស្រីតែឯងនោះទេដំបូងហើយម្តាយរបស់ខ្ញុំនឹងមានកូនចំនួននឹង ៧
នាក់ហើយបងប្អូនរបស់ខ្ញុំនឹងមានសុទ្ធតែប្រុសប្រុសទាំងអស់មានតែខ្ញុំនោះទេដែលជាស្រីតែម្នាក់ឯងចឹងហាសដែលវាមានភាពនឿនហាត់ពេកដល់ពេលចឹងទៅខ្ញុំនឿនហាត់ពេកខ្ញុំក៏បានចាំថ្ងៃខែដែលខ្ញុំបានកើតនឹងខ្លួនឯងដែលចឹងហាសចាសគឺខ្ញុំនឹងភ្លេចអស់ហើយពីព្រោះអីនឹងយើងនឹងវានឿនពេកវាដូចថាយើងនឹងធ្វើការងារលើប្រុសប្រុសនឹងចឹងហាសគឺកំលាំងជាប្រុសតែម្តងខ្ញុំក៏មានបងប្អូនប្រុសដែលក៏ប៉ុនតែគេបានរៀនហើយគេបានទៅបួសនៅឯវត្តឯវ៉ាគេស្នុកអីចឹងតែយើងនឹងបានរៀនតែបន្តិចបន្តួចនឹងបានយើងចឹងបានខ្ញុំនឹងនៅតែផ្ទះចឹងហាសហើយនឹងមានបងប្អូននឹងចំនួន ៩ នាក់
តែស្លាប់នៅជំនាន់ពោលពតគឺពោលពតបានយកបងប្អូនរបស់ចំនួន ២
នាក់ដែលនៅក្នុងជំនាន់ពោលពតហាស៕

ក៖ បាទអ្នកមីងអាចរាប់ឈ្មោះរបស់បងប្អូនរបស់ម្តងមួយមួយបានដែលរឺទេអ្នកមីង???

ខ៖ ចាសបានតា៕

ក៖ បាទទី១គាត់មានឈ្មោះអ្វីដែលអ្នកមីង???

ខ៖ ចាសទី ១ គាត់មានឈ្មោះ ស្រៀង ផាង ហើយទី ២ គាត់មានឈ្មោះ គឺខ្ញុំ ស្រៀង ស្រ៊ុង ហើយទី ៣ គាត់មានឈ្មោះ ស្រៀង ហោង ហើយទី ៤ គាត់មានឈ្មោះ ស្រៀង ហឿង ហើយទី ៥ គាត់មានឈ្មោះ ស្រៀង ងែត ហើយទី ៦ គាត់មានឈ្មោះ ស្រៀង ងួន ហើយទី ៧ គាត់មានឈ្មោះ ស្រៀង មឿន ហើយទី ៨ គាត់មានឈ្មោះ ស្រៀង ស្រឿង
គាត់គឺជាស្រីហាសហើយនឹងទី ៩ គាត់មានឈ្មោះ ស្រៀង ស្រៀង
ហើយសៀងនឹងគាត់គឺជាកូនពៅគេហាស៕

ក៖ បាទហើយលូវតើពួកគាត់បានរស់នៅទៅកន្លែងណាដែលទៅអ្នកមីង???

ខ៖
ចាសនៅនឹងមានតែនៅឆ្ងាយឆ្ងាយនៅឯស្រុកនោះមានចំនួន៣នាក់ហើយនៅប៉ៃលិនឯ
នោះមានចំនួន១នាក់ហើយនៅទកន្លែងនេះមានចំនួន៣នាក់ដែលគាត់ស្រីមិញនឹងហាសខ្ញុំ
គឺខ្ញុំនៅទីកន្លែងនោះទេគឺស្រុកកោះធំហាសស្រុកកោះធំហើយនឹងខេត្តកណ្ដាលចឹងហាស
តែដល់នឹងខ្ញុំវង់វែងពីព្រោះអីប្ដីរបស់ខ្ញុំគាត់បានស្លាប់ចឹងទៅហើយខ្ញុំក៏មានកូនច្រើនទៀតចឹ
ងហើយខ្ញុំក៏មានកូនច្រើនទៀតហើយកូនរបស់ខ្ញុំវានៅតូចហាសចាស់ហើយនៅទីកន្លែង
នោះក៏ខ្ញុំពិបាក់នឹងរកស៊ីរកអីដែលចឹងហាសក៏ខ្ញុំនឹងបាននាំកូនហើយនឹងចៅមកនៅទីកន្លែ
ងនេះដើម្បីរកស៊ីអីនៅទីកន្លែងនេះទៅពីព្រោះអីវានៅជិតផ្សារចឹងហាសហើយខ្ញុំក៏បាននាំម
កដើម្បីរកស៊ីរកអីចឹងទៅកូនរបស់ខ្ញុំហើយខ្ញុំនឹងកូនរបស់ខ្ញុំក៏ចេះតែនៅទៅហើយនៅទីកន្លែ
ងនេះវាជាង ១០ឆ្នាំហើយគ្រាន់តែមកនៅទីកន្លែងនេះហាស៕

ក៖ បាទចឹងអ្នកមីងមានទីកំណើតនៅទីកន្លែងណាដែលទៅអ្នមីង???

ខ៖
ចាសខ្ញុំមានទីកំណើតនៅកោះធំស្រុកធំឃុំរកាដែកគឺនៅឃ្លាំងដែកហើយនឹងខេត្តកណ្ដាល
យើងនឹង៕

ក៖ បាទហើយអ្នកមីងគឺកូនទីប៉ុន្មានដែលទៅអ្នកមីង???

ខ៖ ចាសខ្ញុំគឺកូនទី ២ ៕ព្

ក៖ បាទហើយឪពុកនឹងម្ដាយរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែលទៅអ្នមីង???

ខ៖ ចាសឪពុករបស់ខ្ញុំគាត់មានឈ្មោះថា ស្រៀប ស្រៀង
ហើយនឹងម្ដាយរបស់ខ្ញុំនឹងគាត់មានឈ្មោះ សេង ហ៊្វង ៕

ក៖ ហើយឪពុកនឹងម្ដាយរបស់អ្នកមីងគាត់មានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង???

ខ៖ ចាសគឺឪពុករបស់ខ្ញុំគាត់បានស្លាប់យូរហើយគឺគាត់បានស្លាប់ជាង១០
ហើយនៅតែម្ដាយរបស់ខ្ញុំនោះទេគាត់មានអាយុ៨៨ឆ្នាំហើយតែរាល់ថ្ងៃនឹងម្ដាយរបស់ខ្ញុំគា
ត់បានវង់វែងហើយគាត់ក៏មើលអ្វីមិនសូវជាឃើញដែលទេហើយគាត់បាននៅទេមួយកន្លែង
នោះទេគឺគាត់បានរស់នៅជាមួយនឹងប្អូនពៅរបស់ខ្ញុំហើយខ្ញុំនឹងយូរយូរនឹងខ្ញុំបានទៅម្ដងចឹ
ងហាស៕

ក៖
បាទហើយអ្នកមីងមានបានចាំថាពួកគាត់ទាំអ២បានកើតនៅថ្ងៃណាហើយនឹងខែណាហើ
យនឹងឆ្នាំណាដែលរឺទេអ្នកមីង???

ខ៖
ចាសគឺខ្ញុំមិនចាំនោះទេហេហេហេគឺខ្ញុំមិនដឹងថាគាត់បានកើតនៅឆ្នាំណាហើយនឹងខែណានោះទេចាស៕

ក៖
បាទហើយអ្នកមីងមានបានដឹងថាពួកគាត់ទាំង២នឹងបានកើតនៅទីកន្លែងណាដែលរឺទេអ្នកមីង???

ខ៖
ចាសគឺខ្ញុំដឹងតាម្ដាយនឹងឪពុករបស់ខ្ញុំគឺគាត់ទាំង២បានកើតនៅស្រុកកោះធំដ៏ដែលក៏ប៉ុនតែម្ដាយរបស់ខ្ញុំគាត់បានរស់នៅគ្រោយខាងកើតហើយចំនែកឪពុករបស់ខ្ញុំវិញគាត់បានរស់នៅគ្រោយខាងលិចចាសគឺគាត់បានរស់នៅក្នុងកោះហាសហើយម្ដាយរបស់ខ្ញុំនឹងនៅក្នុងកោះហាសគឺនៅកោះធំនឹងតែម្ដងគឺភូមិកោះធំរបស់គេម៉ងហាសហើយពួកខ្ញុំគាត់រស់នខាងគ្រោយខាងកើយតែនៅខាងគ្រោយក្បាលដំរីភូមិពុងកុងហើយនឹងខេត្តកណ្ដាលនឹងដែលគ្រាន់តែថាម្ដាយរបស់ខ្ញុំនឹងគាត់រស់នៅក្នុងកុងនឹងហើយឪពុករបស់ខ្ញុំនឹងគាត់រស់នៅគ្រោយខាងកើតគឺពួកគាត់រស់នៅទាលមុខគ្នាចឹងហាសហើយគឺស្រុកកំណើតរបស់គាត់ទាំង២គឺនៅទីកន្លែងនឹងតែម្ដងហាសគឺផ្ទាល់ម៉ងហាចាស៕

ក៖ បាទចឹងម្ដាយរបស់អ្នកមីងសព្វថ្ងៃនឹងតើគាត់នៅមានជីវិតដែលរឺទេអ្នកមីង???

ខ៖
ចាសរាល់ថ្ងៃនឹងគាត់គឺកំពុងរស់នៅជាមួយប្អូនរបស់ខ្ញុំហើយគាត់ក៏គ្មានធ្វើអ្វីនោះទេពីព្រោះគាត់នឹងបានវង់វែងវង់វន្ដ
ដែលចឹងហាសហើយគាត់ដើរមិនបាននោះទេហើយអង្គុយតែមួយកន្លែងនឹងទេហើយមើលក៏មិបានឃើញដែលពីព្រោះគាត់ចាស់ហើយគាត់មានអាយុ ៨៧ឆ្នាំ រឺក៏ ៨៨ឆ្នាំ ហើយនឹង៕

ក៖
ហើយចឹងអ្នកមានបានចាំពីជីដូនហើយនឹងជីតារបស់អ្នកមីងគាត់មានឈ្មោះអ្វីដែលទៅអ្នកមីង???

ខ៖ ចាសតារបស់ខ្ញុំគាត់ចាខ្ញុំចាំតាចាសតាខាងម្ដាយរបស់ខ្ញុំគាត់មានឈ្មោះ សេន ឈ្មោះទេសេងហាសតែឪពុករបស់គាត់មិនដឹងជាមានឈ្មោះអ្វីនោះទេពីព្រោះដែលនៅក្នុងជំនាន់ពោលពតដែលខ្ញុំបានកើតមកតាទូតរបស់គាត់បានស្លាប់ហើយហើយខ្ញុំនឹងបានចាំតែតាខាងម្ដាយរបស់ខ្ញុំនឹងហើយតារបស់ខ្ញុំគាត់មានឈ្មោះតាសេង
ហើយយាយរបស់ខ្ញុំគាត់មានឈ្មោះយាយ រ៉ែត
ចាសនឹងខាងម្ដាយរបស់ខ្ញុំនឹងហាសតែប្រសិនខាងឪពុករបស់ខ្ញុំតារបស់ខ្ញុំគាត់មានឈ្មោះតាភាពហើយយាយរបស់ខ្ញុំគាត់មានឈ្មោះយាយ គង់ ហេហេហេ៕

កៈ
បាទហើយចឹងតើអ្នកមីងមានបានចាំពីថ្ងៃខែហើយនឹងឆ្នាំដែលពួកគាត់បានកើតដែលរឺទេអ្នកមីង???

ខៈ
ចាសគឺខ្ញុំមិនបានចាំនោះទេចាសពីព្រោះអីពួកគាត់ចាស់ចាស់អស់ហើយហោហោហោហើយយ៉ាងខ្ញុំនឹងនៅតូចតូចពេកចឹងហាស៕

កៈ បាទចឹងរាល់ថ្ងៃនឹងតើអ្នកមីងមានស្វាមីដែលរឺទេអ្នកមីង???

ខៈ ចាសប្ដីរបស់ខ្ញុំនឹងគាត់បានស្លាប់ជាយូរណាស់មកហើយជាង ២០ឆ្នាំហើយចាហើយនៅពេលដែលប្ដីរបស់ខ្ញុំគាត់បានស្លាប់២០ឆ្នាំនឹងគឺកូនរបស់ខ្ញុំនឹងកើតទើបតែបាន១ខួបនោះទេចាសអាពៅរបស់ខ្ញុំនឹងហាស៕

កៈ បាទហើយស្វាមីរបស់អ្នកមីអគាត់មានឈ្មោះអ្វីដែលទៅអ្នកមីង???

ខៈ ចាសប្ដីរបស់ខ្ញុំគាត់មានឈ្មោះ ព្រឹម មីរ ៕

កៈ ហើយប្ដីរបស់អ្នកមីងគាត់ប្រកបមុខរបបអ្វីដែលទៅអ្នកមីង???

ខៈ
ចាសអត់ទេអូនអើយកាល់ចាសកាល់ពីមុខគាត់បួសហើយគាត់បួសតាំងនៅតូចដូចថាគាត់បិនថៅរបស់ខ្ញុំដែលមកមិញនឹងហាសគាត់នៅតូចដូចថានៅពេលដែលគាត់បួសចឹងហើយគាត់បួសនឹងជាង ៣០ឆ្នាំហើយណាដែលនិយាយសាច់គាត់បានបួសនឹងហាសរហូតមកដល់ដែលគាត់បានមកសឹកហើយគាត់សឹកនៅជំនាន់ពោលពតនេះគេសឹកលោកហាសមានដឹងទេមានដែលបានដឹងដែលចាស់ចាស់គាត់បាននិយាយដែលទេគឺគេសឹកលោកហើយដល់ពេលដែលគេបានសឹកពីលោកចឹងមកដល់ពេលដែលសឹកមកដែលនៅជំនាន់នឹងយើងចូលជិតឆ្នាំ ១៩៧១ ហើយណាហើយចូលមកឆ្នាំ ១៩៧២
ហើយដែលគាត់បានសឹកជាលោកមកនឹងដល់ពេលហើយចឹងទៅគេក៏បានអោយគាត់នឹងទៅធ្វើជាប្រធានភូមិដែលជាប្រធានចូលភូមិចាសកាល់នឹងវានៅក្នុងដែលមានត្រឹមថាអង្គរដែលគេហៅថាក្រុមហ៊ុមក្រុមតាមភូមិចឹងហាសដែលគេបានហៅថាពលកលក្រុមតាមភូមិចឹងហាសអូសសហាកលគឺគេហៅថាសហាករហើយដល់ពេលចឹងទៅវានារីអីចឹងដែលបាននៅនឹងគឺនៅជំនាន់នឹងវាបានចឹងហាសហើយគេលក់ដូរចាយលុយបានហើយគាត់នឹងគេបានអោយគាត់បានធ្វើជាប្រធានភូមិប្រធានអីចឹងទៅណាដល់ពេលហើយនឹងគេមិនរើសប្រធានហើយគេបានចាប់ប្រធានហើយគេបានអោយជននឹងបានប្រមូលបានទៅផ្ទះទាំងអស់ដែលពួកពោលពតបាននិយាយចឹងហាសហើយចូលផ្ទះចឹងហើយគាត់ទៅទៅចឹងទៅហើយគាត់ហើយទៅនៅពេលដែលបានបែកមកវិញដែលបានបែកពួកពោលពតនឹងហាស

បែកនឹងពួកពោលពតមកផ្ទះហើយបានបានមកហើយគាត់ស្នាក់នៅតាំងពីមុខខ្ញុំបានមកប្ដីដែលនៅតាំងពីពួកអាពតហាសតែខ្ញុំមិនបានរៀបអាពាហ៍ពិពាហ៍ហើយខ្ញុំមិនព្រមរៀបអាពាហ៍ពិពាហ៍នោះទេហាហាហាតែដល់ពេលដែលបានបែកហើយបែកពួកពោលពតគាត់ក៏បានមកវិញចឹងទៅក៏ឪពុកហើយនឹងម្ដាយឪពុកក្មេកខ្ញុំនឹងគាត់បានមកហើយក៏បាននិយាយម្ដងទៀតហើយខ្ញុំក៏បានរៀបអាពាហ៍ពិពាហ៍នឹងទៅតែគាត់មិនបានធ្វើអ្វីកើតនោះទេពីព្រោះគាត់បានត្រូវគ្រាប់ចឹងហាសហើយដែលមានអំបែងដែលនៅក្នុងខ្លួនរបស់គាត់ហើយនឹងដៃរបស់គាត់នឹងជើងរបស់គាត់ចឹងហាសពីព្រោះអីគាត់បានត្រូវគ្រាប់គាត់ដូចថាមានរោគអីដែលមាននៅក្នុងខ្លួនរបស់គាត់ចឹងហាសដល់ពេលចឹងទៅមានតែខ្ញុំនឹងដែលចិញ្ចឹមកូនផងអីផងគាត់បានធ្វើជាអាចារបានធ្វើជាអាចារអីចឹងហាសហើយរកនាយអាយអីចឹងអីជួយដើម្បីមកជួយកូនចៅយើងចឹងហាសបានរកស៊ីមានបានចឹងហាសគឺគ្មានធ្វើអ្វីបាននោះទេបានត្រឹមធ្វើជាអាចារបានតែបិននឹងហាហាហាហើយបានធ្វើការងារដូចជាស្ទុងអីដោយឯងហើយធ្វើអ្វីគឺដោយខ្លួនឯងហើយនឹងដកតែបិននឹងហាសហាហាហា៕

កៈ
បាទចឹងអ្នកមីងអត់បានរៀបអាពាហ៍អាពិពាជាមួយនឹងប្ដីរបស់អ្នកមីងទេមែនដែលទេអ្នកមីង???

ខៈ
ចាសគឺខ្ញុំបានបែកហើយបានខ្ញុំបានរៀបអាពាហ៍អាពិពាហ៍បែកហើយយើងបែកនឹងមិនឆ្នាំ ១៩៧៣ ចឹងហាសបែកហើយបានចំនួន ៥ ខែបានខ្ញុំបានរៀបអាពាហ៍អាពិពាហ៍៕

កៈ បាទហើយអ្នកមីងបានរៀបអាពាហ៍អាពិពាហ៍នៅឆ្នាំណាដែលទៅអ្នកមីង???

ខៈ យើងគ្រាន់ឆ្នាំ ១៩៧៣ នឹងគ្រាន់តែបែកបានប្រហែលជា ៥ខែនឹងគឺយើងបានរៀបអាពាហ៍អាពិពាហ៍នឹងអានឹងនៅក្នុងឆ្នាំ១៩៧៣ គឺមិនទាន់បានចូលឆ្នាំ ១៩៧៤ ទេណាចាសគឺនៅក្នុងឆ្នាំ ១៩៧៣ នឹងហាស៕

កៈ បាទចឹងអ្នកមីងបានរៀបអាពាហ៍អាពិពាហ៍ជាមួយប្ដីរបស់អ្នកនៅក្នុងឆ្នាំ១៩៧៣ ហើយអ្នកមីងបានរៀបអាពាហ៍អាពិពាហ៍ជាមួយស្វាមីរបស់អ្នកមីងបានរៀបអាពាហ៍អាពិពាហ៍ដោយស្មាក់ចិត្តរឺក៏ឪពុកម្ដាយរបស់គាត់គឺជាអ្នកបង្ខំអ្នកមីងដែលរឺក៏យ៉ាងមិចដែលអ្នកមីង???

ខៈ
ចាសនិយាយទៅគឺឪពុកម្ដាយរបស់ខ្ញុំនឹងគឺគាត់បង្ខំហាហាហាចាសពីព្រោះអីខ្ញុំថាខ្លួនថាមិនយកចឹងហាសតែយើងចេះតែស្ដាប់ពាក្យទូលមានរបស់ឪពុកម្ដាយចឹងចេះតែយកទៅចាស៕

ក៖
បាទហើយចឹងនៅពេលដែលបានរៀបអាពាហ៍អាពិពាហ៍ថាតើអ្នកមីងបានយកថ្លៃបនណាការនឹងចំនួនប៉ុន្មានដែលទៅអ្នកមីង???

ខ៖
ចាសគឺគ្មាននោះទេកាល់នឹងដូចថាអង្ករគឺគេយកអង្ករមកចងដៃនៅឡើយហើយគឺយើងជួយគ្នាហើយនៅជំនាន់គឺយើងនៅមិនទាន់មានលុយកាត់ចាយនៅឡើយនោះទេចាសយើងបែកឆ្នាំ ១៩៧៣ ចូលឆ្នាំ ១៩៧៤ ជិតចូលឆ្នាំ ១៩៧៥ បានគេចាប់ផ្ដើមចាយលុយចឹងហាសហើយនៅពេលដែលយើងចាយលុយនឹងគឺយើងនៅចាយលុយដុងទៀតចាសគឺជាលុយរបស់យួនហាសចាសគឺមិនទាន់មានលុយខ្មែររបស់យើងចាយនោះទេតែនៅពេលដែលខ្ញុំបានរៀបអាពាហ៍អាពិពាហ៍នឹងគឺគេមិនទាល់ចាយលុយនោះទេចេះតែជួយគ្នាទៅវិញទៅមកចឹងទៅណាហេហេហេ៕

ក៖ បាទសំណួរដែលខ្ញុំចង់សួរទៅកាន់អ្នកមីងបន្ថែមទៀតថាតើនៅជំនាន់ឆ្នាំ ១៩៧៣ តើអ្នកមីងមានបានរៀនសូត្រអ្វីដែលបន្ថែមទៀតអីដែលរឺទេអ្នកមីង???

ខ៖ ហ៊ឹមកាល់នៅឆ្នាំ ១៩៧៣ នឹងគឺវាហួសហើយដែលនៅពោលពតនឹងហាសពីព្រោះអីខ្ញុំបានរៀនសូត្រតាំងពីមុនជំនាន់ពោលពតមកម្លេះហើយកាល់ដែលខ្ញុំបានរៀនសូត្រនឹងកាល់ពោលពតនឹងតាំងពីខ្ញុំមានអាយុ ១២ឆ្នាំ មកម្លេះហើយមិនដឹងជាឆ្នាំណានោះទេតែដូចជាឆ្នាំ ១៩៦០ ជាងហេចាសដូចជា ១៩៦០ ទេចាសគិតមើលកាល់ដែលខ្ញុំរៀននឹងគឺខ្ញុំបានរៀនកាល់ដែលខ្ញុំមានអាយុ ១២ឆ្នាំ ខ្ញុំបានចូលរៀនចាសចឹងគឺឆ្នាំ១៩៦០ ចាស៕

ក៖
បាទចឹងនៅពេលដែលអ្នកមីងបានទៅរៀនសូត្រចឹងថាតើនៅក្នុងជំនាន់នឹងអ្នកមីងគឺជាសិស្សពូកែរឺក៏ជាមធ្យមរឺក៏ជាសិស្សដែលខ្សោយរឺក៏យ៉ាងមិចដែលអ្នកមីង???

ខ៖
ចាសខ្ញុំប្រសិនជារៀនសូត្រខ្ញុំគឺរៀនសូត្របានពូកែដែលនឹងហាសគ្រាន់តែថាខ្ញុំនឹងមិនបានរៀនសូត្រជាប់លាប់ចឹងហាសពីព្រោះថាចេសពេលដែលឪពុករបស់ខ្ញុំគាត់មានជំងឺឪពុករបស់ខ្ញុំគាត់កាល់ដែលនៅជំនាន់អ៊ីសារាក់គឺគាត់បានត្រូវគ្រាប់ត្រូវអីចឹងហាសហើយដល់ពេលចឹងទៅគឺគាត់ធ្វើការងារអ្វីមិនបាននោះទេហើយនៅពេលដែលគាត់ធ្វើការងារមិនបានចឹងគឺខ្ញុំហើយនឹងប្អូនប្រុសរបស់ខ្ញុំហើយប្អូនរបស់ខ្ញុំវាទៅធ្វើការងារចឹងចឹងវាមិនបានរៀននោះទេហើយវាទៅមើលគោចឹងទៅហើយនៅពេលដែលគាត់បានឈឺចឹងទៅខ្ញុំក៏ទៅភ្ជួលដីហើយនឹងលីដីហើយចេះតែភ្ជួលដីចឹងទៅណាហើយយើងមិនសូវជារៀនសូត្របានជាប់លាប់នោះទេហើយដែលនៅជំនាន់គឺខ្ញុំនឹងបានរៀនសូត្របានថ្នាក់ទី ១០ ចាសគឺថ្នាក់ទី ១០ពីដើមហាសហើយកាល់ថ្នាក់ទី

១០ដែលនៅជំនាន់នឹងគឺបានខ្ពស់ដែលតែនៅពេលដែលខ្ញុំមើលនៅពេលដែលខ្ញុំមើលរួចហើយខ្ញុំមើលអក្សរបងរបស់ខ្ញុំនឹងគឺមើលរួចហើយដូចជាអក្សរបារាំងអីចឹងគឺខ្ញុំមើលរួចហាសតែមកដល់លូវនឹងគឺខ្ញុំនឹងរឺរូកអីចឹងទៅគឺខ្ញុំមានអារម្មណ៍ថាគឺខ្ញុំភ្លេចអស់ហើយហើយនៅពេលដែលខ្ញុំភ្លេចហើយគឺនៅពេលដែលខ្ញុំមើលនឹងអក្សរនឹងនៅដែលមើលនឹងគឺវាជាប់គ្នាហើយគឺមិនបានដឹងថាវាជាអក្សរអ្វីអក្សរអ្វីនោះទេចាសគឺវាជាប់គ្នារហូតហោហោហោចាសកន្លែងដែលយើងមើលបានគឺយើងមើលបានចឹងហាសតែកន្លែងណាដែលយើងមើលមិនដាច់អក្សរនឹងវាជាប់គ្នាតាតាច់ម៉ងពីព្រោះអីភ្លែករបស់ខ្ញុំនឹងគឺវាឆាប់ស្រវឹងអីចឹងហាសហើយនៅពេលដែលយើងលូវនឹងចឹងពេលមើលគឺឃើញតែខ្មៅខ្មៅគឺមើលមិនសូវឃើញនោះទេខ្ញុំគឺកូនរបស់ខ្ញុំនឹងបានយកខ្ញុំនឹងទៅមើលអស់ហើយគឺអស់លុយចំនួន ១០០$ រឺក៏ ២០០$ ហាសបានខ្ញុំនឹងបានមើលគេមើលឯងបានឃើញចឹងហាសហើយអាជើងរបស់ខ្ញុំនឹងគឺវាឈឺហើយនឹងចុកមើលទៅដូចជាទូរាំទំរាយណាស់ចាសនិយាយទៅគឺពិបាក់៕

ក៖

បាទចឹងអ្នកមីងកាល់នៅជំនាន់នឹងអ្នកមីងគឺមិនសូវជារៀនសូត្របានជិតដល់នោះទេហើយមូលហេតុអ្វីដែលដែលអ្នកមីងរៀនសូត្របានជិតដល់ដែលអ្នកមីង???

ខ៖

ចាសមូលហេតុដែលខ្ញុំរៀនសូត្របានជិតដល់នោះគឺមកពីខ្ញុំនឹងវានឿនហត់ហើយនឹងរវល់មើលប្អូនមើលប្អូនផងហើយខ្ញុំទៅភ្ជួលហើយនឹងបានបាច់ដីបាច់អីចឹងហាសគឺគេអោយទៅធ្វើចឹងទៅហើយនៅពេលដែលបានមករៀនអក្រាកម្មចឹងទៅនៅតែខ្ញុំរៀនសូត្រមិនបានល្អដ៏ដែលពីព្រោះអីម្ដាយរបស់ខ្ញុំនឹងគាត់មានជំងឺហើយគាត់បានកើតបោះចាសគឺគាត់បានឈឺហើយឈឺនឹងគឺឈឺហើមហាសហើយឪពុករបស់ខ្ញុំនឹងកាល់ដែលនៅជំនាន់អ៊ីវាក់នឹងហាសចាសកាល់នឹងគឺគេបានហៅថាថារដ្ឋអាណានិគមបារាំងហាសហើយមានគេធ្វើលំបិនចឹងទៅគឺគាត់បានទៅធ្វើជាទាហ៊ានចឹងទៅគឺផ្ទុះគ្រាប់បែកហើយនៅពេលដែលផ្ទុះគ្រាប់បែកចូលខ្លួនរបស់គាត់ចឹងហាសហើយនៅពេលដែលគាត់ឈឺម្ដងម្ដងគឺគាត់មិនហ៊ានកោលខ្យល់នោះទេហើយប្រសិនជាយើងនឹងហ៊ានតែកោលខ្យល់នឹងគឺគាត់ដឹងតែឈឺតែម្ដងគឺឈឺសៀកដើមទ្រង់របស់គាត់ចឹងហាសចាសគឺនៅពេញខ្លួនរបស់គាត់គ្រាប់នឹងក៏នៅហើយនឹងអំបែងនឹងក៏នៅក្នុងខ្លួនរបស់គាត់ចឹងហាសដូចថានៅពេញខ្លួនរបស់គាត់ចឹងហាសចឹងទៅដូចគាត់ចង់ធ្វើអ្វីក៏មិនបានចឹងហាសចាសគឺគាត់អ្វីក៏មិនបានដល់ពេលចឹងទៅគឺមានតែខ្ញុំនឹងចេះតែធ្វើការងារចឹងទៅហើយចំនែកបងប្រុសរបស់ខ្ញុំគាត់មានគេបង្រៀនចឹងហាសគឺលោកបានបង្រៀនហើយចំនែកប្អូនរបស់ខ្ញុំគឺពូកគាត់នឹងនៅតូចតូចចាសប្អូនរបស់ខ្ញុំនឹងហាសដល់ពេលដែលអាប្អូនទី៣របស់ខ្ញុំចាសបានតែអាមួយនឹងទេបានមួយនឹងបានជួយមើលគោមើលអីចឹងហាសហើយអាបន្ទាប់ទៀតនឹងគឺវាខ្វិនហើយអានឹងគឺអាប្អូនពៅអាវេទនាណាស់ចាសយ៉ាប់ណាស់ហើយដល់ពេលដែលអោយប្ដីអោយធូរអោយស្រួលអីគឺអត់ទេនៅតែពិបាក់ដ៏ដែលហើយនៅពេលដែលប្ដីក៏នៅតែនឿននៅតែនែយហើយរកចិញ្ចឹមកូនរកអីនឹងមិនចង់នឹងរស់ផងចាស៕

កៈ
បាទចឹងអ្នកមីងមានបានចងចាំពីសាលារៀនរបស់អ្នកមីងមានឈ្មោះអ្វីដែករឺទេអ្នកមីង???

ខៈ ចាសគឺខ្ញុំបានរៀននៅសាលារៀនកោះធំ៕

កៈ បាទសាលារៀនកោះធំជាវិទ្យាល័យរឺក៏សាលាបថមដែលអ្នកមីង???

ខៈ
ហ៊ឹមនៅសាលារៀនកោះធំគឺជាសាលាបថមដែលគេបានចូលហូលហៃកចឹងចាសកាល់នឹង គឺមិនទាន់ចូលដល់មហាវិទ្យាល័យនោះទេចាសប្រសិនជាវិទ្យាល័យគឺនៅឯងគ្រោយម្ខាង ខាងគ្រោយរមេះឯនោះទេ៕

កៈ
បាទចឹងអ្នកមីងក្រៅពីភាសាខ្មែរនឹងថាតើអ្នកមីងមានចេះភាសាផ្សេងទៀតទេក្រៅពីភាសា ខ្មែរហាសអ្នកមីង???

ខៈ
ចាសនៅជំនាន់នឹងខ្ញុំចេះភាសាវៀតណាមតែមកដល់នឹងគឺខ្ញុំនឹងបានផភ្លេចអស់ហើយហេ ហេហេចាសកាល់ដែលខ្ញុំនៅពីក្មេងនឹងគឺខ្ញុំចេះតាគឺតារបស់ខ្ញុំគាត់បានបង្រៀនខ្ញុំចឹងហាស ចាសតារបស់ខ្ញុំគាត់បានបង្រៀនខ្ញុំដល់ពេលដែលខ្ញុំចាសហើយដល់ពេលដែលខ្ញុំនឹងហាត់ ពេកហើយនឹងនឿនពេកចឹងទៅគឺខ្ញុំបានភ្លេចអស់តែម្តងហាសចាសកាល់ពីមុខខ្ញុំចេះតាគឺខ្ញុំ ចេះភាសាច្រើនណាស់ហាសតែមកដល់លូវក៏ខ្ញុំចេះដែលតែខ្ញុំនឹងចេះតែបន្តិចបន្តួចចាសដូ ចប្រសិនជាអោយខ្ញុំនិយាយដូចជាស្លឹងគ្រៃហើយនឹងចង្កៀងអីនឹងគឺខ្ញុំនឹងនៅចាំតាហេហេ ហេ???

កៈ
បាទហើយចឹងអរគុណច្រើនមែនទែនអ្នកមីងចឹងសំណួរដែលខ្ញុំចង់សួរទៅកាន់អ្នកមីងបន្ថែ មទៀតថាតើអ្នកមីងមានបញ្ហាអ្វីបន្ថែមទៀតថាតើជីវភាពដែលមាននៅក្នុងជំនាន់ពោលពត ហាសអ្នកមីងអាចប្រាប់ខ្ញុំបានដែលរឺទេអ្នកមីង???

ខៈ
ចាសខ្ញុំដែលនៅក្នុងជំនាន់ពោលពតវាលំបាក់គឺវាលំបាក់គឺលំបាក់ហើយគ្រាន់គ្រង់ថាដែល នៅក្នុងជំនាន់តាមភូមិហើយឃុំចឹងហាសដូចគេថាចឹងនៅពេលដែលទៅភូមិឃុំណាដែល ស្រួលអីស្រួលអីចឹងទៅគឺវាស្រួលហើយហើយកន្លែងដែលមិនស្រួលគឺមិនស្រួលនោះទេដូ ចកន្លែងខ្ញុំចឹងគឺភូមិឃុំខ្ញុំចឹងហាសប្រជាជនរបស់ខ្ញុំនឹងគឺគេអោយហូបបបរហូបអីចឹងហាស ចាសហើយខ្ញុំគឺនៅអង្គភាពចាសគឺខ្ញុំនៅអង្គភាពហើយគេអោយយើងទៅរែកដីរែកដីចឹង ទៅអានឹងដូចគេចង់ដកយើងទៅទីកន្លែងណាចឹងទៅគឺតាមតែគេចឹងទៅណាចាសគឺតាម តែចិត្តរបស់វាតែម្តងហើយវានឹងបញ្ជាយើងនឹងតែម្តងហើយយើងនឹងចេះតែធ្វើការងារទៅ

តែប្រសិនជាយើងមិនធ្វើតាមពួកវាទេគឺពួកវានឹងយកសំលាប់យើងចោលដល់ពេលចឹងទៅដូចថាយើងនឹងនៅក្រោមបង្គាប់វាចឹងទៅយើងចេះតែធ្វើទៅហើយខ្ញុំនឹងវាគ្រាប់មុខហើយវាលំបាក់ងាក់ទៅធ្វើការងារនេះផងចឹងទៅហើយងាក់ទៅធ្វើការងារនោះទេចឹងទៅកគ្រួសាររបស់ខ្ញុំពួកគេនៅតូចតូចហើយចិញ្ចឹមហើយមានពេលខ្លះអត់មានអ្វីនឹងហូបចុកចឹងទៅហាសហើយនៅពេលដែលខ្ញុំអត់មានអីចឹងទៅខ្ញុំនឹងចេះតែសុំគេចឹងទៅហាសនេះពិបាក់ណាស់នៅពេលដែលសុំគេហាសតែប្រសិនជាក្រៅពីខ្ញុំអីនឹងគឺវាយ៉ាប់ហើយហើយចខ្ញុំនឹងចេះតែនិយាយទៅកាន់ប្រធានភូមិប្រធានអីចឹងណាស់គឺខ្ញុំសុំគេហើយខ្ញុំបាននិយាយថាឪពុករបស់ខ្ញុំគាត់ឈឺហើយខ្ញុំនឹងក៏ឈឺចឹងហាសគឺខ្ញុំទៅសុំអង្ករគេហើយនៅពេលដែលបានខ្ញុំសុំបានមកចឹងទៅក៏បានដាំហូបហើយក៏ចែកគ្នាហូបចឹងទៅពីព្រោះអីគេចែកនឹងគឺបានម្នាក់បានតែ២ខាំតែប៉ុនណ្ណោះចាសគឺយើងទទួលបានម្នាក់២ខាំគ្រាប់គ្នាចឹងហាសចាសហើយតែបានមេឃុំគាត់បានអោយខ្ញុំបានមកបន្ថែមទៀតចឹងហាសគឺគាត់បានអោយបន្តិចចឹងហាសអោយយើងបានយកមកដាំបាយបានហូបចឹងទៅតែប្រសិនតាមនេះអីសុទ្ធតែយ៉ាប់យ៉ាប់ណាសតែខ្ញុំនឹងវានឿនណាស់នៅពេលដែលនៅក្នុងជំនាន់ខ្ញុំក៏មានភាពលំបាក់គ្រាប់នាយគ្រាប់សាប់ចឹងហាសហើយយើងមើលតែយើងមួយថ្ងៃមួយថ្ងៃគឺយើងនឹងហត់ចឹងស្លាប់ហើយហេហេហេដេកមិនលក់ទេមួយយប់មួយយប់៕

ក៖
បាទហើយចឹងនៅក្នុងជំនាន់ពោលពតនឹងថាតើអ្នកមីងបានរស់នៅទីកន្លែងណាវិញដែលទៅអ្នកមីង???

ខ៖
ចាសគឺខ្ញុំបានរស់នៅទីកន្លែងនឹងដំដែលនឹងគឺខេត្តកណ្តាលនឹងតែម្តងគឺនៅក្នុងស្រុកកោះធំនឹងតែម្តងដូចថាគេមិនបានបញ្ជូលយើងទៅនេះនោះដែលឆ្ងាយហាសប្រសិនជាអ្នកទៅគេក៏បានបញ្ជូលទៅបានឆ្ងាយចឹងទៅរហូតដល់មានពេលខ្លះបញ្ជូលទៅដល់ខេត្តព្រៃវែងចឹងទៅហាសតែសំរាប់ខ្ញុំវិញគឺគ្មានទេគឺខ្ញុំរស់នៅតែក្នុងស្រុកនឹងតែម្តងហាសដូចបានថាបានធូរមួយកំរិតចឹងទៅដូចជាថាយើងនឹងគឺវានឿនហត់ពេកហើយចឹងទៅហាសដូចថាពួកពោលពតវាមិនបានអោយយើងនឹងបានរែកដីរែកអ្វីនោះទេគឺវាអោយយើងរែកចូសចុះបើលពេលព្រឹកព្រឹមឡើងគឺដល់ម៉ោង ១១ រឺក៏១២
អីនឹងគឺយើងនឹងបានឈប់សំរាប់ហូតបាយបានតែ១ម៉ោងនោះទេហើយបន្ទាប់មកពីនឹងគឺពួកវាបានអោយយើងនឹងចាប់ផ្តើមធ្វើទៀតហើយចឹងហាសដូចថាយើងនឹងបានចិញ្ចឹមកូនហើយនឹងបានចិញ្ចឹមចៅរបស់យើងចឹងទៅហាសចាសដូចថាកាល់នៅក្នុងជំនាន់ពោលពតនឹងគឺយើងនឹងរកកន្លែងដែលបានស្រួលនឹងគឺវាគ្មាននោះទេអ្នកណាក៏ដូចជាអ្នកណាដែលគឺគ្មានស្រួលនោះទេចាសនិយាយទៅគឺមានភាពពិបាក់ណាស់៕

ក៖
បាទចឹងហើយនៅក្នុងជំនាន់នឹងថាតើអ្នកមីងគេមានបានអោយអ្នកមីងបានធ្វើអ្វីដែលពីបាក់ពីបាក់សំរាប់អ្នកមីងដែលរឺទេអ្នកមីងដែលអ្នកមីងមិនចង់ធ្វើហាស????

ខ៖
ចាសគឺគ្មានអ្វីដែលពីបាក់នោះទេគឺមិនបានអោយយើងនឹងធ្វើនោះទេតែយើងនឹងវាអោយយើងនឹងចេះតែធ្វើការងារបានគ្រាប់មុខចាសគឺគមានដែលពីបាក់នោះទេគ្រាន់តែខ្ញុំដូចថាពួកពោលពតនឹងពួកវាបានដកយើងនឹងបានចេញទៅចឹងហាសគឺអោយយើងនឹងបានធ្វើការងារដែលស្រួលស្រួលចឹងហាសហើយនៅពេលដែលខ្ញុំបានចូលទៅកាន់ក្នុងនឹងការងារដែលលំបាក់ពេកចឹងហាសហើយពួកពោលពតវាបានអោយយើងនឹងទៅធ្វើជ្រែលគឺអោយទៅធ្វើជ្រែលចឹងហាសតែគេក៏បានសួរយើងដែលហាសតើមាននរណាដែលចេះធ្វើទៅធ្វើជ្រែលរឺទេរឺក៏ជ្រកធ្វើជ្រែលដែលរឺទេដែលជាម្សៅធ្វើជ្រែលហាសដល់ពេកនឹងអ្នកដែលរស់នៅជាមួយនឹងខ្ញុំចឹងគតាត់បានប្រាប់ថាខ្ញុំនឹងចេះធ្វើម្សៅជ្រែលនឹងតែប្រសិនជាខ្ញុំមិនបានឆ្លើយនឹងក៏យើងនឹងវាហាត់ដែលចឹងហាសអោយតែយើងនឹងចេះនឹងគឺយើងនឹងហាត់ហើយចឹងហាសហើយពេលនឹងអ្នកដែលបានរស់នៅជាមួយខ្ញុំគាត់ក៏បានប្រាប់គេថានេះមិត្តម្នាក់នេះគាត់ចេះធ្វើម្សៅជ្រែលនេះហើយខ្ញុំនឹងគឺចេះធ្វើម្សៅជ្រែលនឹងបានមួយចប់ចឹងហាសហើយដល់ពេលដែលគេបានដឹងថាយើងចេះធ្វើម្សៅជ្រែលចឹងទៅគេក៏បានដាក់អោយធ្វើការងារនឹងគឺកាន់ខាងជ្រកជ្រែលនឹងហាសហើយដល់ពេលចឹងទៅនារីនារីគ្នាដែលរស់នៅដែលគេមិនបានចេះចឹងទៅយើងនឹងចេះតែបង្រៀនហើយនឹងអោយគេធ្វើតាមយើងចឹងទៅអោយតែយើងនឹងបានរស់ចឹងហាសចុះយើងធ្វើមិចធ្វើយ៉ាងណាអោយតែយើងនឹងបានរស់ហើយនឹងបានរស់ចឹងហាសហើយប្រសិនជាយើងនឹងមិនព្រមធ្វើហើយយើងនឹងនៅតែជចេះនឹងគឺយើងនឹងមានទុសហើយពេលនឹងគឺគេនឹងយើងនឹងទៅសំលាប់ចោលទៀតចឹងទៅយើងទ្រាំមធ្វើទៅហើយពេលនឹងខ្ញុំចេះធ្វើម្សៅជ្រែលនឹងតែម្តងទៅតែប្រសិនជាគិតទៅយើងរៀនកាល់ដែលខ្ញុំនៅរៀនគឺខ្ញុំបានមករៀននៅកោះធំនឹងកាល់ឆ្នាំទៅគេហើយដល់ពេលចឹងទៅខ្ញុំដូចជាខ្ញុំរៀនចឹងរៀនចឹងទៅគឺកាល់នៅរៀននឹងគឺនៅខាងផ្ទះដែលនៅខាងកើតឯនេះទេហើយតារបស់ខ្ញុំគាត់បួសជាលោកហើយគាត់ក៏បានអោយខ្ញុំនឹងរៀននៅឯផ្ទះរបស់គេហើយរៀននៅឯវត្តកោះហើយនៅពេលដែលខ្ញុំរៀនហើយនៅពេលដែលខ្ញុំបានចេញពីរៀនគឺខ្ញុំក៏បានមកផ្ទះយាយរបស់ខ្ញុំហើយខ្ញុំក៏បានធ្វើម្សៅជ្រែលនឹងហើយនឹងខ្ញុំក៏បានជួយគាត់គឺជួយធ្វើម្សៅជ្រែលនឹងហាសហើយខ្ញុំក៏បានត្បាយកន្ទេយចឹងទៅហើយដល់ពេលដែលយប់ឡើងចឹងទៅគឺខ្ញុំធ្វើម្សៅជ្រែលនឹងហើយនៅដែលចេញពីរៀនគឺជ្រកម្សៅជ្រែលដល់ហើយបានទៅរៀនវិញហើយដល់ដែលយើងនឹងបានចូលពោលពតចឹងពួកពោលពតដឹងថាយើងនឹងចេះធ្វើម្សៅជ្រែលនឹងពួកពោលពតនឹងក៏អោយយើងនឹងធ្វើម្សៅជ្រែលនឹងតែម្តងហោហោហោតែគ្រាន់តែថាការងារនឹងវាពីបាក់ហើយនឹងមានច្រើនតិចហើយភូមិនឹងវាចាប់អោយរ៉ែតដីចាសគឺមានតែប៉ុននឹងហើយនៅពេលដែលអោយយើងហូបនឹងក៏ពួកវាបានអោយយើងនឹងហូបបានច្រើនដែលចឹងហាសចាសគឺអត់ដូចគ្នាដែលជាអ្នកដែលទៅរ៉ែតទៅអី

ចឹងហាសសុទ្ធតែរោបាយនឹងចានហាសរោចានរោអីចឹងទៅហើយនៅពេលដែលខ្ញុំនិយាយនឹងក៏ខ្ញុំយំដែលពីព្រោះអីប្អូនរបស់ខ្ញុំពួកវានៅតូចតូចអីចឹងហាសហើយនៅដែលចូលមណ្ឌលអីនឹងសុទ្ធតែរោចានហាសហើយបបរពោតហាសចាសបបរពោតមើលបានខ្ញុំនឹងនៅពេលដែលខ្ញុំជ្រកជ្រែលចឹងប្រធានប្រធានឃុំប្រធានភូមិនឹងអាមេឃុំនឹងវាបានហៅខ្ញុំនឹងក៏បានហៅខ្ញុំមកនេះគឺហៅពួកខ្ញុំហើយនៅពេលដែលពួកគាត់បានហៅខ្ញុំចឹងទៅគាត់ក៏បានអោយអង្ករហើយនឹងអោយជាស្ករមកដល់ខ្ញុំចឹងទៅហើយនឹងម្សៅជ្រែលចឹងទៅហើយគាត់បានថាទុកយកទៅហូបចឹងទៅហាសចាសគឺធូរបានតែប៉ុននឹងទេតែប្រសិនជាបងទី៣របស់ខ្ញុំគាត់បានចូលនឹងនឹងគឺគេហៅថាខាងភារៈមហាជនចឹងហាសចាសគឺខាងយុវជននឹងហាសកងពល១រឺក៏កងពល២ចឹងទៅចាសយ៉ាប់ហាសប្អូនប្អូនរបស់ខ្ញុំហើយបងរបស់ខ្ញុំអីនឹងគឺថាពីបាក់ដែលតែយើងមិដឹងជាធ្វើយ៉ាងមិចដែលយើងនៅក្នុងជំនាន់នឹងហាស៕

ក៖

បាទហើយថានៅក្នុងជំនាន់ពោលពតនឹងថាតើគេមានអោយអ្នកមីងទៅដកស្ទុងហើយនឹងធ្វើស្មៅអ្វីផ្សេងទៀតដែលរឺទេអ្នកមីង???

ខ៖

ចាសដកតាដូចថាយើងធ្វើមួយវគ្គចឹងគឺយើងធ្វើជ្រែលចឹងគឺយើងធ្វើមិនបានរាប់ឆ្នាំនោះទេចាសដូចថាពេលដែលយើងធ្វើបាន៩ថ្ងៃរឺក៏បាន១០ថ្ងៃចឹងទៅគឺគេបានដកយើងនឹងចេញហើយគឺគេបានដកយើងនឹងទៅស្ទុងហើយស្ទុងនឹងគឺគេសុទ្ធតែរោសអោយយើងចឹងហាសចាស១០នាក់គឺគេអោយយើងនឹងធ្វើ១ហិតតា១០នាក់គឺគេអោយយើងនឹងធ្វើ១ហិតតាហើយធ្វើយ៉ាងមិចអោយហើយមួយព្រឹកនឹងតែម្ដងចាសតែមួយព្រឹកហាសគឺគេបានដាក់គេបានដាក់វិន័យអោយយើងធ្វើនឹងអោយហើយក្នុង១០នាក់គឺគេអោយយើងនឹងធ្វើ១ហិតតានឹងម៉ងចាសហើយគិតមើលមើលដី១ហិតតានឹងចំនួនប៉ុន្មានហើយដាក់អោយនឹងប៉ុន្មានអាចំនួនប៉ុន្មានម្នាក់ចឹងហាសហើយខ្ញុំនឹងស្ទុងខ្ញុំម្នាក់នឹងហើយម្នាក់ដូចថាពីត្រឹមសសរនឹងទៅដល់នឹងចឹងហាសតែសំរាប់ខ្ញុំវិញគឺគេអោយខ្ញុំនឹងធ្វើពីការខាងក្រោយមកវិញចឹងហាសហើយខ្ញុំនឹងធ្វើដាច់មកមុខទៀតបានបានឡើងហូបបាយតែប្រសិនជាមិនបានធ្វើអោយហើយក្នុងចំនួន១ហិតតានឹងគឺគេមិនបានអោយយើងនឹងឡើងទៅហូបបាយនោះទេចឹងក៏ចឹងបានថាយើងផ្ដាំទៅដល់កូនកូនថាអោយខំរកកាល់ដែលនៅក្នុងជំនាន់ម្ដាយគឺម្ដាយលំបាក់ហើយនឹងវេទនាខ្លាំងណាស់ចាសគឺមិនបានស្រណុកនោះទេហើយទំរាំបានហូបបាយបានមួយពេលនឹងគឺយើងត្រូវធ្វើការងារក្នុងមួយថ្ងៃគឺធ្វើរហូតហើយនឹងខំប្រឹងណាស់និយាយទៅគឺគ្មាននឹងម៉ោងសំរាប់នឹងសំរាប់នោះទេហើយប្រសិនជាយើងនឹងស្ទុងដីនឹងមិនបានមួយហិតតានឹងគឺមិនបានឡើងហូបបាយនោះទេហើយនយើងត្រូវតែធ្វើអោយហើយអោយគេចឹងហាសហើយប្រសិនជាគេបានកំណត់ដល់ម៉ោង១១ដែលពួកវាបានអោយយើងឡើងចឹងហាសហើយប្រសិនជាយើងធ្វើការងារហួសម៉ោង១១នឹងគឺយើងគ្រាន់តែឡើងទៅហូបបាយហើយគឺយើងបានត្រូវតែចុះទៅវិញទៀតហើយចឹងបានថាខ្ញុំនឹងនៅឈឺចាប់រហូតមកដល់សព្វថ្ងៃនឹងហាសចាសខ្ញុំនឹងនៅឈឺចាប់ឈឺចាប់ត្រង់ថាប្អូនរបស់ខ្ញុំពួកពោលពតវាបាន

ធ្វើបាប់ហើយប្អូនរបស់ខ្ញុំវាបានស្លាប់ហើយគ្នាវានឹងមានចំនួន៣នាក់ដែលពួកវានៅពេលឡាលានឹងមានគ្នាចំនួន៣នាក់ហើយបងរបស់ខ្ញុំគឺបងធររបស់ខ្ញុំនឹងហ៊ឹមបងរបស់ខ្ញុំធររបស់ខ្ញុំនឹងក៏ពួកវាបានសំលាប់ដែលចឹងហាសទើបតែស្លាប់ហើយប្ដីហើយនឹងកូនហើយឪពុករបស់ខ្ញុំពួកពោលពតពួកវាចង់រកទៅដែលតែកុំតែបានប្អូនរបស់ខ្ញុំវាបានឡើងមកទាន់ចឹងហាសចាសកុំអីនឹងពួកពោលពតនឹងវាយកទៅសំលាប់ចោលបាត់ហើយវាចឹងហាសចាសយើងដែលនៅក្នុងជំនាន់នឹងយើងចេះតែធ្វើហើយនឹងចេះតែដូចចាសបុរាណបាននិយាយថាយើងអោនយើងដាក់គ្រប់ហើយនៅដែលយើងឈរអោយត្រូវចេះឈរចាសដល់ចឹងទៅគឺយើងមានតែចេះទ្រាំទៅចាសគឺនាំគ្នាអោនក្បាលទៅហើយចេះតែធ្វើទៅដើម្បីកុំអោយស្លាប់ចឹងទៅដល់ពេលដែលចឹងទៅគឺខ្ញុំនឹងមានភាពឈឺចាប់ខ្លាំងណាស់ហើយខ្ញុំចេះតែនឹកឃើញហើយខឹងដូចថាឡឺស្វរឿងពោលពតអាពតគឺខ្ញុំនឹងចេះតែខឹងខឹងវាមានភាពឈឺចាប់ខ្លាំងណាស់ហើយគឺថាស្លាប់បងស្លាប់ប្អូនដែលស្លាប់ជាគ្រួសាររបស់ខយើងចឹងហាសចាសកូនរបស់ខ្ញុំនឹងមានចំនួន២នាក់ហើយមារបស់ខ្ញុំនឹងមានចំនួន៣នាក់ហើយបងរបស់ខ្ញុំនឹងគឺអស់មួយសំបុកហើយកូនចិញ្ចឹមរបស់ឪពុកខ្ញុំនឹងក៏បានស្លាប់ដែលចឹងហើយដល់ពេលចឹងទៅហាស៕

ក៖
បាទហើយចឹងនៅក្នុងជំនាន់ពោលពតគេតើអ្នកមីងបានខអ្វីខ្លះអំពីការបាញ់សំលាប់អំពីអ្វីដែលគេបានអូសទាញយកទៅសំលាប់ដើម្បីយកទៅសំលាប់ចឹងហាសអ្នកមីង???

ខ៖
សំរាប់ខ្ញុំដែលនៅក្នុងជំនាន់នោះវាដូចថាវាគឺថាយើងសូមបីតែយើងនឹងនិយាយអ្វីដែលខុសអ្វីតិចនឹងក៏អត់បានដែលហើយនៅពេលដែលយើងនិយាយអ្វីដែលឆ្គងអ្វីតែបន្តិចអីនឹងក៏ពួកវាយកយើងនឹងទៅសំលាប់ចោលដែលហាសចាសនឹងហើយដូចថាយើងធ្វើការងារអីចឹងនៅពេលដែលយើងទៅធ្វើចឹងដែលមិនទាន់ពេលវេលាអីចឹងក៏ពួកវាចាប់យើងយកទៅដាក់គក់ដាក់ច្រវាក់ដែលចឹងហាសគឺវាចឹងហាសបានថានេះខ្ញុំមៀលមៀលរបស់វាគឺបងជីទូតមួយរបស់វានឹងហាសចាសគឺ៧នាក់ដែលពួកវាយកទៅសំលាប់ហាសវាគ្មានអីនោះទេដូចថាគ្នាវាធ្វើការងារអីដែលមិនទាន់ចឹងហាសចាសគឺគ្នាទៅមិនទាន់គេចឹងហាសចាសគឺវាហៅគ្នាទៅហើយយើងប្រសិនបើថាដល់ម៉ោងស្រាងស្រាងអីចឹងហាសគឺថាម៉ោង៦អីនឹងគឺត្រូវតែអោយដល់កន្លែងវាចឹងហាសគឺត្រូវតែដល់កន្លែងវាចឹងតែម្ដងហើយអោយតែដល់ម៉ោង៥អីនឹងគឺយើងចាប់ផ្ដើមក្រោកហើយហើយគ្នាវាមិនស្វរជាស្រួលខ្លួនអីចឹងទៅហើយមៀលខ្ញុំគាត់បានសុំគេសុំឈប់ថាគាត់មិនស្វរជាស្រួលខ្លួនអីចឹងគឺគេថាមិនអោយនោះទេគឺវាត្រូវតែអោយយើងទៅជាដាច់ខាតហើយនៅពេលដែលយើងធ្វើមិនកើតគឺវាក៏ចាប់ផ្ដើមយកយើងទៅដាក់ច្រវាក់ហើយក៏ចាប់ផ្ដើមវៃចោលហើយខ្ញុំនឹងដែលក្នុងជំនាន់នឹងគឺថាវាពិបាក់ខ្លាំងណាស់ពីព្រោះអីឃើញបងប្អូនដូចថាវាស្លូតអស់ចឹងហាស៕

កៈ
បាទចឹងអ្នកមីងអាចប្រាប់ទៀតបានទេថាតើនៅពេលជំនាន់នឹងដែលក្រោមអាណានិគមរបស់បាំរាំងចឹងថានៅជំនាន់ដែលគេមកជួយមករំដោះយើងហើយនៅពេលដែលគេបានជួយរំដោះយើងហើយថាតើគេជំលាសយើងទៅណាហើយយ៉ាងមិចទៀតដែលអ្នកមីងតើអ្នកមីងអាចជួយប្រាប់ខ្ញុំបានដែលរឺទេអ្នកមីង???

ខៈ ចាសអានឹងគឺយើងបានចូលឆ្នាំ ១៩៧៣
ហើយបានដូចថាបានបែកចេញមកដូចថាគឺកងទ័ពរបស់វៀតណាមនឹងបានរំដោះយើងចឹងហាសនឹងចេះចាប់មើលហាសវាក្នុងថ្ងៃនឹងហ៊ីមដូចថ្ងៃទីប៉ុន្មានទេដូចជាភ្លេចហើយចឹងពីព្រោះអីដែលពួកពោលពតវាបានដាក់ផែនការអោយយើងទៅបានជួបជុំគ្នាដែលនៅទៅកន្លែងអណ្តូងនឹងហាសហើយក៏ជាថ្ងៃដែល១៧មករាចាសអានឹងគឺដល់ថ្ងៃ១៧មករាហើយចាសពីព្រោះពួកពោលពតពួកវាបានដាក់ផែនការ១៧មករានឹងគឺត្រូវជាថ្ងៃដែលបានបែកហើយក៏វាត្រូវជាថ្ងៃដែលពួកពោលពតបាននាំប្រជាជនរបស់យើងនឹងហើយនាំចូលទៅកាន់អណ្តូលហើយហាសចាសហើយចូលអណ្តូលនឹងវាព្រាបនឹងវៃហើយពួកវាបានជីកអល្លូងហើយហើយថាអោយយើងនឹងចូលទៅហើយអោយយើងហូតនំបញ្ចុកអីចឹងហាសហើយបន្ទាប់ពួកវាសំលាប់យើងចាសនឹងហើយតែដូចថាបានកងទព័វៀតណាមរបស់បានមករំដោះយើងហើយក៏ក្រោយបានឡើងមកណាស់ហើយនៅពេលដែលបានឡើងមកនឹងក៏បានគេនឹងទំលាក់គ្រាប់បែកនឹងចុះមកហើយវាក៏បានបញ្ចៀសមកនឹងក៏វាបានបាញ់មកលើស្វរដឹងហើយបានយើងនឹងបានរួចហើយម្នាក់ម្នាក់នឹងក៏បានរត់យកព្រះអាយុហើយក៏បានរត់មកផ្ទះមកសំបែងរៀងរៀងមកចាសហើយដូចជារូបខ្ញុំនឹងខ្ញុំបានរត់មកហើយខ្ញុំក៏បានដើរប្រមូលប្អូនប្អូនរបស់ខ្ញុំចាសប្អូនរបស់ខ្ញុំគឺវានៅនេះអាពីមុខអាម្ចាស់ដីនេះគឺនៅក្នុងមណ្ឌលដែលគេខ្មៀលគោហាសចាសហើយពេលនឹងគឺគេមិនអោយគាត់បានចេញគឺគេមិនអោយគាត់បានចេញហើយអាប្អូនរបស់ខ្ញុំនឹង២នាក់នឹងហ៊ីមអាមួយនឹងហ៊ីមអាគេមិនអោយចេញហើយដល់ពេលខ្ញុំនឹងក៏បានរត់ពីខ្លាលត់មកក៏បានអង្ករនឹងមួយកញ្ជើលអង្ករនឹងមួយកញ្ជើលដែលមេភូមិគេបានអោយមកខ្ញុំចាសគឺប្រធានភូមិហាសចាសគេបានអោយបានអង្ករនឹងមួយកញ្ជើលខ្ញុំក៏បានទូលមកទូលមកហើយខ្ញុំនឹងក៏បានមកមុខគេហើយនៅពេលដែលខ្ញុំបាមមកដល់ផ្ទះខ្ញុំក៏បានដាក់អង្ករនឹងដាក់នៅឯផ្ទះចោលហើយខ្ញុំនឹងរត់ទៅរកហ៊ីមចាសគឺរត់ទៅរកប្អូនរបស់ខ្ញុំហើយនៅពេលដែលខ្ញុំទៅរកប្អូនរបស់ខ្ញុំឃើញបានប្អូនរបស់ខ្ញុំហើយទៅឃើញវាហើយតែគេមិនបានអោយចេញនោះទេចាសគឺវាមិនអោយចេញហើយពួកវានឹងវាប្រុងនឹងបញ្ចេញប្អូនរបស់យើងឆ្លងទៅឯនោះគឺទៅឯខាងលិចទៀតនោះហើយនៅពេលដែលពួកវាបានបញ្ចូលឆ្លងនឹងគឺបំណងនឹងរបស់ពួកវាដែលបានអោយយើងបានទៅនឹងទៅរស់រឺក៏ពួកវាយកទៅសំលាប់ពោលទន្លេរហើយអ្នូនឯដែលលឺចាស់ចាស់និយាយអំពីពោលទន្លេរទេចាសនឹងហើយគឺមន្ទីពោលលលានឹងហើយបញ្ចូលពីនឹងមកនឹងហើយកើបហើយនឹងសំលាប់នៅទីកន្លែងនឹងតែម្តងចាសគឺមកវៃនៅទីកន្លែងនឹងតែម្តងហើយខ្ញុំហាសបានឃើញទៅទៅបានឃើញប្អូនហើយតែគេមិនបានអោយចេញចាសគឺគេនៅតែឃាំងមិនព្រមអោ

យចេញដល់ពេលហើយក៏នឹកឃើញហ៊ុមពួកនេះប្រុងបញ្ចូលប្អូនរបស់អញ់ទៅណាមកអីចេះចាសហើយគឺនឹកឃើញចឹងក៏រត់ទៅរត់ទៅអ៊ុំមួយអ៊ុំមួយឈ្មោះអ៊ុំសែហើយនៅពេលដែលបានទៅអ៊ុំនឹងបានអ៊ុំនឹងគាត់បានមកហើយនៅពេលអ៊ុំនឹងបានមកគឺគាត់បាននិយាយថាកុំទាន់អាចាំនាំពួកវាចេញហាសអាមេមេនឹងហើយដល់អាមេនឹងគេបាននាំគ្នាចេញមកចឹងទៅបានខ្ញុំនឹងទៅគាស់អាទ្វាររបស់វានឹងគឺខ្ញុំបានគាស់អាទ្វាដែលគេបានគាតក្មេងក្មេងនឹងដែលជាក្មេងមណ្ឌលនឹងហាសចាសថាអាមណ្ឌលនឹងគឺវានៅពេញនឹងតែម្តងចាសហើយប្រសិនជាពួកពោលពតពួកវាវៃនៅទីកន្លែងនឹងត្រូវតែសំលាប់ទាំងអស់ម៉ងចាសគឺវាបានឃាំងហើយខ្ញុំនឹងបានទៅគាស់ម៉ងចាសគឺខ្ញុំនឹងបានទៅគាស់២នាក់អ៊ុំសែនឹងចាសខ្ញុំទៅនាំគ្នាគាស់គាស់ចេញមកបានចាសគឺខ្ញុំនឹងបាននឹកឃើញអាពេលដែលបានលើកអង្គរនឹងមកចាសគឺខ្ញុំនឹងវាកំសត់ពេកចុះអាប្អូនដែលក្មេងក្មេងកូនរបស់គេកូនរបស់យើងចាសគឺយំទាំងអស់គ្នាចាសគឺយំចេញមកចាសដល់ពេលហើយហើយដល់ដែលខ្ញុំបាននឹកឃើញមកចាសគឺខ្ញុំអាណិតប្អូនរបស់ខ្ញុំពេកចាសខ្ញុំនាំមកហើយបានចេញអស់មកចឹងទៅស្រាប់តែវានឹងបានចាប់ខ្ញុំនឹងវានឹងបានចាប់ខ្ញុំហើយវាបានខ្ញុំនឹងគឺជាអ្នកដែលបានលួចគាស់អោយក្មេងក្មេងទាំងអស់បានចេញចឹងហាសហើយដល់ពេលហើយខ្ញុំនឹងក៏បាននឹកឃើញថាខ្ញុំនិយាយវានិយាយអង្វរវានឹងហាសហើយខ្ញុំថាហ៊ុមអោយគ្នាបានចេញសិនទៅចាសអោយគ្នាបានចេញសិនទៅរួចហើយប្រសិនបើលជាពូឯងគិតបិទក្មេងក្មេងហើយពូឯងគិតនឹងប្រុងធ្វើយ៉ាងមិចហើយនៅពេលដែលខ្ញុំបាននិយាយចឹងក៏ពួកអ្នកដែកធ្វើការងារចឹងចាសគឺដូចគេធ្វើការងារដែលនៅខាងនឹងដែលតែពួកវាមិនបានទៅខាងនឹងទេពួកវាហាសចាសគឺពួកវាមិនរត់ទៅទីកន្លែងនោះទេដូចថាគេនៅដែលគេចង់ជួយប្រជាជនយើងចឹងហាសហើយដល់ពេលដែលពួលវាបានឃើញពួកវាបានមកចឹងក៏ពួកវាបានប្រលេងខ្ញុំចាសហើយខ្ញុំនឹងវាជិតនឹងសំលាប់ចោលដែលនៅក្មេងក្មេងហាស៕

ក៖
បាទចឹងនៅពេលដែលអ្នកមីងទៅដល់ជំរំនឹងហើយបានគាស់ទ្វានឹងនឹងដើម្បីជួយក្មេងក្មេងនឹងហើយពួកគេបានចាប់ផ្តើមចាប់អ្នកមីងហើយនៅពេលដែលចាប់អ្នកមីងហើយអ្នកមីងធ្វើយ៉ាងមិចទៀតដែលអ្នកមីងដើម្បីនឹងគេចរំដោះដែលទៅអ្នកមីង???

ខ៖
នឹងគឺចាប់ខ្ញុំទុក្ខគឺមិនអោយខ្ញុំនឹងទៅណាមកណានោះទេចាសហើយខ្ញុំបាននៅសុំអង្វរគេដែលពួកគេដែកបានរស់នៅទីកន្លែងនឹងចឹងហាសហើយគេគ៏ជាធ្វើការងារដែលតែគ្រាន់តែថាគេបានមក៤រឺក៏៥នាក់ចឹងទៅហើយពួកវាក៏បានលេងខ្ញុំហើយពួកវាក៏បានចេញទៅចាសអានឹងគឺមេភូមិរបស់គេចឹងហាសគាត់គឺជាមេឃុំខាងត្រាំងកក់យើងនឹងហាសចាសគឺគាត់បានមកធ្វើមេឃុំនៅទៅកន្លែងនឹងមួយឈ្មោះអាលុន
ហើយអាទី២ឈ្មោះអាខៀងចាសបានពូឪតាពួពូឪនឹងគាត់នៅស្តៅហាសចាសផ្ទះហើយនឹងស្រុកកំណើតរបស់គាត់នឹងគឺនៅព្រៃស្តៅហាសចាសដែលពួកគាត់នៅព្រៃស្តៅនឹងបានមិត្តភត្តិរបស់បានមក៤រឺក៏៥នាក់គឺពួកគាត់នឹងចាសបានពួកគាត់នឹងបានគេនឹងប្រលេងខ្ញុំចាស

កុំអីនឹងពួកវាមិននឹងប្រលេងយើងនោះទេកុំតែបានពួកគាត់នោះទេហើយពួកគាត់នឹងក៏ជា
នាក់ដែលបានជាប់គក់នៅឯវត្តិពោលលលាដែលចាសគឺបានពួកគាត់នឹងដែលបានជួយរំ
ដោះក្មេងក្មេងនឹងអីនឹងកុំអីនឹងពួកនឹងគឺវៃងាប់ទាំងអស់នឹងចាសគឺបានពួកគាត់ទេជាអ្នកជួ
យនោះទេគាត់បានជួយដោះហើយនឹងបានជួយប្រលេងហើយបាននាំគ្នានឹងបានចេញគាត់
អោយនាំគ្នាទាំងអស់ទៅផ្ទះទៅហើយអ្នកណាដែលដើររួចទៅក៏ទៅទៅហើយអ្នកណាដែល
ដើរមិនរួចអីចឹងទៅគាត់ក៏បានផ្តាំផ្ញើរអោយទៅអ្នកទៅនឹងអោយបងប្អូននឹងអោយពួកគាត់
នឹងបានមកយកចឹងទៅហាសវត្តិពោលលលានឹងកុំអីនឹងគឺពួកវានឹងវៃងាប់ទាំងអស់នឹងចា
សគ្រាន់តែខ្មោចនឹងគឺនៅពេញផ្ទះចាសគឺពេញនៅលើផ្ទះចាសវត្តិពោលលលាហើយសំរាប់
ហាសបានទៅយកអង្ករទៅក្បែរជើងនឹងហើយទៅរកដើម្បីយកអីយកអីនឹងគេហើយខ្ញុំបាន
ឃើញភ្លើងនឹងហើយបានឃើញសុទ្ធតែក្បាលខ្មោចចាសដែលពេញនៅលើផ្ទះហាសផ្ទះវត្តិ
ពោលលលានឹងគឺសុទ្ធតែក្បាលខ្មោចចាសហើយប្រសិនជាខ្ញុំនិយាយពីប្រវត្តិពួកពោលពត
វាជិតនឹងងាប់ហើយតែសំណាងដែលដោយសារតែយើងបានជួយរកប្អូនគឺជួយប្អូនរបស់
យើងហាសចាសហើយក្មេងក្មេងវាមានចំនួនច្រើនដែលនឹងហាសចាសគឺចូលជិត២០នាក់
ដែលមានក្មេងក្មេងតូចនឹងជិត២០នាក់ហើយទៅបានតាសែននឹងគឺគាត់បានមកចំនួន២នា
ក់ចាសបាន២នាក់គាត់បានក្មេងក្មេងនឹងបានចេញមកចឹងហាសចាស៕

កៈ
បាទចឹងនៅពេលដែលអ្នកមីងបានទៅដល់ហើយបានឃើញសុទ្ធតែក្បាលខ្មោចចាសដែល
ពេញនៅលើផ្ទះចឹងតើអ្នកមីងមានអារម្មណ៍យ៉ាងមិចអ្នកមីងរត់ពីកន្លែងនឹងរឺក៏អ្នកមីងនៅតែ
ទៅរកបងប្អូនរបស់អ្នកមីងទៀតរឺយ៉ាងមិចដែលអ្នកមីង?

ខៈ
ចាសគឺខ្ញុំមិនបានទៅរត់ទៅណានោះទេគឺខ្ញុំនឹងនៅតែបើកភ្លើងនៅមើលហើយនឹងដើរមើល
ពេញក្នុងផ្ទះចឹងហាសចាសឃើញសុទ្ធតែក្បាលខ្មោចចាសដែលពេញនៅលើផ្ទះដែលពួកវា
បានវៃចឹងហាសចាសហើយនៅពេលដែលវាវៃហើយគឺវាទៅបាត់ចាសដល់ដែលវាវៃហើយ
គឺវាទៅបាត់ទៅដល់ពេលហើយពួកខ្ញុំដែលជាប្រជាជននឹងក៏បាននាំគ្នានឹងទៅវត្តិពោលល
លាហើយក៏ចេះតែទៅទៅហើយក៏បានយកស្រូវហើយនឹងអង្ករខ្លះអីចឹងទៅហើយនឹងអំបិល
ទៅហូបចឹងទៅហាសចាសពីព្រោះអីកាល់នឹងបែកហើយណាចាសនិយាយទៅគឺបានឃើ
ញអ្វីគឺយកនឹងទៅហាសចាសហើយខ្លះទៅគេក៏បានក្រណាត់ហើយនឹងខោអាវហើយបាន
អីចឹងទៅហើយអ្នកខ្លះទៀតគេក៏បានម៉ាស៊ីនដេរអីចឹងគេបានចឹងហាសឃើញអ្វីចេះតែយក
ទៅហាសពីព្រោះអ្វីកាល់ដែលនៅក្នុងជំនាន់នឹងវាពួកបានប្រមូលពីភូមិរបស់យើងនឹងទៅទុ
ក្ខនៅទៅកន្លែងនឹងចឹងហាសគឺវត្តិពោលលលានឹងចាសគឺពួកវាបានយកទៅទុក្ខគរនៅទីក
ន្លែងតែម្តងហើយពីណាពីណាមកគឺពួកវាបានប្រមូលមកហើយនឹងមាសហើយនឹងប្រាក់អី
នឹងគឺពួកវាបានប្រមូលយកមកគរនៅទីកន្លែងនឹងម៉ងចាសគឺគេពេញទីកន្លែងនឹងគឺវត្តិពោ
លលលាហើយខ្ញុំបានឃើញបែកតឹងហើយអ្នកដែលនៅវត្តិពោលលលានឹងគេក៏បានទៅ
ហើយគេបានមាសចំនួន១គីឡូរហាសហើយទៅយកមៀលរបស់ខ្ញុំហើយនឹងពូរបស់ខ្ញុំអីនឹ

ងចាសកាល់នឹងបានមាសនិយាយសូមបីតែកាយតែនឹងក្រណាត់នឹងក៏បានដែលនិយាយទៅវាដុះហាសវាហើយពួកវាបានយកទៅចាក់ចោលនៅទីកន្លែងនឹងម៉ងហើយនឹងប្រមូលហើយនឹងប្រមែលយកទៅចោលហើយនឹងគរនៅទីកន្លែងតែម្តងដូចថាយើងនឹងដែលយើងជាប្រជាជននឹងដែលយើងមានមាសតែបន្តិចបន្តួចហើយើងនឹងចង់ទុក្ខអីនឹងគឺមិនបានទេហាសចាសគឺពួកវាបានមកហើយនឹងប្រមែលហើយនឹងមកប្រមូលរបស់យកទៅលាក់ចឹងហាសហើយនៅពេលដែលយើងមិនបានអោយពួកវាចឹងពួកវាក៏បានចាប់ផ្តើមចាប់យើងហើយនឹងវៃយើងចោលចឹងហាសកាល់នឹងហើយដល់ពេលចឹងទៅយើងនឹងអោយពួកវាហើយពួកវាបានប្រមូលយកទៅទុក្ខចោលចឹងទៅចាសគឺទុក្ខវត្តិពោលលលាយើងនឹងហើយនៅពេលដេលបែកតឹងចឹងទៅមិនដឹងថាមកពីណាហើយនឹងមកពីណើនោះទេចាសគឺគេទៅវត្តិពោលលលាដើម្បីទៅយករបស់ហើយនឹងរបបនៅទីកន្លែងនឹងចាសឆ្នោលនឹងវត្តិពោលលលាចាសដែលគេកំពុងបែកនឹងគេទៅទីកន្លែងនឹងតែម្តងបាននឹងហាស៕

កៈ

បាទចឹងនៅពេលដែលអ្នកមីងបានទៅវត្តិពោលលលានឹងថាតើអ្នកមីងមានបានប្រមូលអ្វីខ្លះដែលពីវត្តិពោលលលានឹងដែកអ្នកមីង???

ខៈ

ចាសនៅពលដែលខ្ញុំបានទៅវត្តិពោលលលានឹងគឺខ្ញុំបានប្រមូលបានតែស្រូវ៦បាវតែប៉ុនណ្ណោះចាសហើយនឹងអំបិលនឹងបាន១បាវហើយនឹងយកបានចាននឹងមានចំនួននឹង៥០ចានហើយហើយមានតែប៉ុននឹងហើយចំនែកបងរបស់ខ្ញុំវិញគឺគាត់បានទៅយកត្រីដែលមានចំនួន១ក្រតិនចាសគឺបានតែប៉ុននឹងហេហេហេគឺគាត់បានឃើញម៉ាស៊ីនម៉ាអីនឹងម៉ាក្រនរតែគាត់មិនយកពីព្រោះគាត់បានថាខ្លាចគេបានមកវិញចឹងគេនឹងសំលាប់យើងហាសតែខ្ញុំបាននិយាយថាគេមិនបានមកវិញទៀតទេពីព្រោះអីនឹងមានគេបានយកអីវ៉ាន់បានច្រើនគ្នាហើយខ្ញុំមានណាគឺខ្ញុំបានប្រមូលស្រូវបានតែប៉ុននឹងចាសគឺខ្ញុំនឹងបានប្រមូលស្រូវតែចំនួន៦បាវនឹងហើយដល់ពេលហើយទៅប្រមូលស្រូវនឹងនៅវត្តពោលលានឹងបានស្រូវតែចំនួន៦បាវទេចាសហើយដល់ដែលខ្ញុំទៅផ្ទះនឹងបាន៣ថ្ងៃខ្ញុំក៏បានទៅវត្តថ្មីនោះដែលខ្ញុំមានមិត្តភត្តិរបស់ខ្ញុំនឹងដែលបានរស់នៅកំពុងធំហើយខ្ញុំនឹងក៏បានទៅវត្តថ្មីសន្សំស្រូវដែលនៅវត្តថ្មីនឹងហាសចាសហើយនៅពេលដែលខ្ញុំបានទៅដល់ទីកន្លែងនឹងឃើញបាញ់ចោលនៅឯវត្តថ្មីនឹងហាសហើយនៅថ្ងៃក្រោយមកទៀតគេក៏បានដែលស្រូវគេមិនទាល់បានជ្រូតនឹងហាសចាសហើយយើងនឹងក៏បានទៅក្រោយគេហើយក៏បានឃើញគេគឺជាអ្នកដែលគេប្រុងនឹងយកអស់នោះចាសគឺយើងសន្សំបានក្រោយគេហើយពេលនឹងប្រធានភូមិនឹងគាត់ក៏បានដើរមកគេក៏បានយកខ្លះខ្លះចឹងហាសហើយនៅពេលដែលបានមកវិញចឹងមកវិញដែលបានរ៉ែកស្រូវមកបានជួបនឹងកងពទ័ជនជាតិវៀតណាមចាសជួបនឹងកងពទ័ជនជាតិវៀតណាមនឹងហាសសរួចហើយខ្ញុំនឹងក៏បាននិយាយភាសាវៀតណាមដាក់ទៅកាន់ចឹងទៅហើយពេលកងពទ័ជនជាតិវៀតណាមក៏បានអង្អែលហើយនឹងស្ទាបក្បាលរបស់ខ្ញុំហើយកងពទ័ជនជាតិវៀតណាមក៏បាននិយាយជាភាសាជនជាតិវៀតណាមថា (ឌីឌី) ដែលប្រែជាភាសាខ្មែរបានថា

អោយទៅទៅហើយនៅទីកន្លែងនឹងគឺគ្មានអ្នកដែលចេះភាសាកងពទ័ជនជាតិវៀតណាមនឹងទេ៥រឺ៦នាក់គឺភ័យគ្រប់គ្នាគ្រាន់តែបានឃើញកាប់ភ្លើងភ្លេមចឹងហាសហើយយកកាប់ភ្លើងពីកងពទ័ជនជាតិវៀតណាមដែលគេបានប្រើសកងពទ័ពួកពោលពតហាសចាស៕

កៈ
បាទហើយចឹងនៅពេលដែលគេបានបាញ់គ្នាដែលនៅក្នុងជំនាន់ពោលពតនឹងនៅពេលដែលអ្នកមីងបានជួបនឹងកងពទ័ជនជាតិវៀតណាមគេក៏បានអោយអ្នកមីងបានទៅជាភាសាជនជាតិវៀតណាមហើយដល់ពេលដែលគេបានអោយអ្បកមីងទៅចឹងថាតើបានជួបនឹងកងទ័ពពោលពតអ្វីទៀតដែលរឺទេរឺក៏យ៉ាងមិចដែលអ្នកមីង???

ខៈចាសគឺខ្ញុំមិនបានជួបនឹងពួកពោលពតទៀតទេនៅពេលដែលមកវិញតែដែលនៅតាមភ្នំគឺខ្ញុំបានឃើញពួកវាដែលបាន
រត់ទៅឡើងទៅលើភ្នំចឹងហាសហើយនៅពេលដែលបានមកវិញក៏បានឃើញកងពទ័ជនជាតិវៀតណាមហើយនៅពេលដែលពួកកងពទ័ជនជាតិវៀតណាមមកចឹងហាសគេក៏បានមិនបានព្រមអោយខ្ញុំនឹងបានមកចឹងហាសហើយកងពទ័ជនជាតិវៀតណាមក៏បានសួរយើងនឹងថាយើងនឹងបានមកពីណាហើយមកពូខេត្តណាអីចឹងទៅហើយគេក៏បានឆែកឆៀយយើងទៅខ្លាចយើងនឹងមានគ្រាប់បែកអីចឹងទៅហាសហើយដល់ពេលដែលយើងនិយាយប្រាប់គាត់ចឹងទៅខ្ញុំក៏បាននិយាយប្រាប់គាត់ថាខ្ញុំនឹងបានមកពីទីកន្លែងសន្សំស្រូវចាសគឺយើងនឹងបាននិយាយជាភាសាខ្មែរហាសមកពីទីកន្លែងសន្សំស្រូវតែកងពទ័ជនជាតិវៀតណាមពួកគាត់ស្តាប់យើងមិនបានហើយនៅពេលដែលពួកគាត់ស្តាប់យើងមិនបានចឹងទៅខ្ញុំនឹងក៏បាននិយាយភាសាវៀតណាមបានមួយម៉ាត់អីនឹងហើាយគាត់បានអោយយើង (ឌី) ដែលប្រែថាអោយយើងទៅទៅចាសហើយកាល់នឹងខ្ញុំនៅចេះហើយនឹងនៅចាំខ្លះហាសហើយមកដល់លូវនឹងគឺខ្ញុំបានភ្លេចអស់ហើយតិចនិយាយអីទៅដូចនិយាយថាសឹងតែមិនរួចតែម្តងហាសហេហេហេតែកាល់ពីមុខអីនឹងគឺខ្ញុំនិយាយបានច្រើនណាស់ហាសចាសគឺនឹងខ្ញុំចេះបានច្រើនភាសាវៀតណាមហើយម៉្យាងទៀតនៅពេលដែលបានខ្ញុំនឹងបានចេះនឹងខ្ញុំចាសកាល់ដែកខ្ញុំនឹងនៅក្រមុំចាសកាល់នឹងខ្ញុំក៏បានចុះទៅជាមួយនឹងមីងរបស់ខ្ញុំនឹងដែលមុនពោលពតនឹងហាសមុនពោលពតខ្ញុំក៏បានទៅដឹកស្វាយចុះទៅខាងក្រោមដឹងទៅកស្រុកភ្នំពេញដែលជាស្រុកហាអាងអីនឹងចាសគឺខ្ញុំនឹងបានទៅទីកន្លែងនោះហើយខ្ញុំក៏បាននិយាយអីជាមួយនឹងគេហើយខ្ញុំនឹងក៏បានចេះហើយដល់ពេលដែលមកដែលយើងបានចូលឆ្នាំ ១៩៧១ រឺក៏ឆ្នាំ ១៩៧២
អីនឹងហើយពេលនឹងកងពទ័ជនជាតិវៀតណាមក៏បានឡើងមកហាណាយអីនឹងហាសក៏បានឡើងមកតាមព្រៃហើយនឹងតាមភូមិអីចឹងចាសហើយប្អូនរបស់ខ្ញុំដែលបន្ទាប់ពីខ្ញុំនឹងចាសគឺវានឹងចេះភាសាជនជាតិវៀតណាមេច្រើនណាស់ច្រើនមែនទែនចាសហើយពួកគាត់នឹងចេះតែមកលេងផ្ទះរបស់ខ្ញុំចឹងហើយខ្ញុំក៏បានរៀននិយាយតាមហើយក៏បានចេះខ្លះចឹងហាសហេហេហេចាសគឺបានចេះបានខ្លះតែបើលមកនិយាយលូវនឹងគឺខ្ញុំនឹងភ្លេចអស់ហើយហេហេហេ៕

ក៖
ចឹងអរគុណច្រើនមែនទែនអ្នកមីងបាទចឹងសំណួរដែលខ្ញុំចង់សួរទៅកាន់អ្នកមីងបន្ថែមទៀតថាតើនៅពេលដែលអ្នកមីងបានបែកពីជំនាន់ពោលពតហើយថាតើអ្នកមីងបានត្រឡប់មកផ្ទះវិញចឹងខ្ញុំចង់អោយអ្នកមីងបានចែកចាយអំពីបទពីសោធន៏ដែលជារឿងល្អល្អនៅដែលអ្នកមីងបានបែកពីជំនាន់ពោលពតហើយថាតើអ្នកមីងមានបទពីសោធន៏ដែលជារឿងល្អល្អសំរាប់ចែកចាយដែលរឺទេអ្នកមីងដូចជារឿងក្រុមគ្រួសារដូចជាបានរៀបអាពាហ៏ពិពាហ៏ហើយនឹងបានរៀបអាពាហ៏ពិពាហ៏អោយកូនរបស់អ្នកមីងហើយនឹងបានរៀបអាពាហ៏ពិពាហ៏អោយរបស់អ្នកមីងចឹងហាសអ្នចកមីង???

ខ៖
នឹងខ្ញុំចាសគឺខ្ញុំបានរៀបអាពាហ៏ពិពាហ៏អោយកូននឹងគ្រាន់តែថាយើងនឹងគ្មានប្ដីនៅជាមួយចឹងហាសចាសដូចថាយើងនឹងតែឯងចឹងហាសយើងមេម៉ាយអោយកូនរបស់យើងគឺយើងមានតែពឹងបងប្អូនរបស់យើងចឹងហាសចាសអោយពួកគាត់បានជួយចឹងទៅតែគ្រាន់តែថាយើងនឹងវាយ៉ាប់ត្រង់ពីជីវភាពរបស់យើងចឹងហាសពពីព្រោះយើងបានរកហើយនឹងរកចិញ្ចឹមកូនរបស់យើងចាសទំរាំមបានកូននឹងបានធំធាត់ចាសគឺបានមកដល់ទីកន្លែងនឹងគឺមកទីកន្លែងនឹងហាសបានខ្ញុំនឹងមានកូនហើយនឹងសីអីនឹងចាសហើយពីនោះមកគឺបានមកពីស្រុកមកដែលងាយស្រួលនឹងធ្វើហើយកូនម្នាក់នេះវាបានទៅស៊ីឈ្នួលគេនៅឯអូរឬស្សីចាសនៅផ្សារអូរឬស្សីហើយម្នាក់នេះវានៅតូចហើយវានៅរៀនចាសនៅរៀនចឹងទៅមានចំនួន៣នាក់ខ្ញុំហាសហើយប្រសិនជានិយាយអាប្រុសប្រុពួកវាមានប្រពន្ធរៀងវខ្លួនដូចថាគេបានរកប្រពន្ធដល់ខ្លួនរបស់គេចឹងទៅហាសចាសគឺខ្ញុំនឹងគ្មានអ្វីនឹងជួយនោះទេចាសគឺប្រពន្ធរបស់វាគឺដោយខ្លួនរបស់វាហើយសំរាប់ខ្ញុំនឹងវិញគឺខ្ញុំនឹងបាននឿនហាត់ណាស់ហើយនឹងបានដល់កំលាំងរបស់ខ្ញុំហើយហាសហេហេហេចាសដូចល្ងវនឹងចឹងគឺខ្ញុំនឹងបានរស់នៅតែ២នាក់កូនរបស់ខ្ញុំចឹងទៅចាសដល់ពេលចឹងទៅចេះតែរកអីនឹងតែម្នាក់ឯងបានតែបន្តិតបន្តិតចឹងទៅហាសពីព្រោះអ្វីដែលពួកគាត់មានប្ដីហើយនឹងប្រពន្ធអស់ហើយនឹងចាសគឺខ្ញុំនឹងបានរស់នៅតែ២នាក់កូន៣របស់ខ្ញុំចាសគឺចេះតែរករកអីចឹងទៅហាសហេហេហេ៕

ក៖
បាទចឹងនៅពេលដែលអ្នកមីងបានរស់នៅជាមួយនឹងក្រុមគ្រសាររបស់អ្នកមីងចឹងថាតើអ្វីទៅដែលជាភាពសប្បាយរបស់អ្នកមីងហាសតើអ្នកមីងអាចចែកចាយប្រាប់ខ្ញុំដែលបានរឺទេអ្នកមីង???

ខ៖
ចាសអ្វីដែលខ្ញុំនឹងមានភាពហើយនឹងសប្បាយនឹងគឺថាគឺវាមិនសូវជាចង់មានភាពដែលពិបាក់ហេហេហេហេគឺខ្ញុំនឹងតែមានភាពសប្បាយរីករាយនឹងតែម្ដងតែម៉ងចាសហើយរាល់ថ្ងៃនឹងប្រសិនជាគេនឹងក៏ដោយសំរាប់ខ្ញុំវិញគឺខ្ញុំនឹងចង់នឹកយលញតែភាពសប្បាយរីករាយចាសហើយសំរាប់ខ្ញុំនឹងទោះបីអត់មានក៏ដោយតែសំរាប់ខ្ញុំនឹងនៅតែចង់មានភាពសប្បាយរីក

រាយហេហេហេចាសហើយទោះបីជាមានហូបនឹងក៏ខ្ញុំនឹងចង់មានភាពសប្បាយរីករាយដែលហាសចាសហើយចិត្តរបស់ខ្ញុំនឹងដូចថាមានអារម្មណ៍ចង់អោយមានកូននឹងបានវាមានហើយនឹងមានភាពនឹងរុងរឿងចឹងហាសចាសណោពេលដែលពួកវានឹងបានប្រលងហើយនឹងបានដាក់ពាក្យរាំមនឹងហាសចាសគឺកូនរបស់ខ្ញុំនឹងអាប្រុសនឹងហាសគឺសំរៀងរបស់វានឹងគឺមានភាពរឹងរុសចឹងហាសចាសហើយខ្ញុំនឹងចូលចិត្តតែបទដែលជារបស់លោកស៊ីនស៊ីសាមុតចឹងហាសចាសគឺពីដើមចាសហើយពីមុននឹងខ្ញុំនឹងក៏ចឹងដែលហើយខ្ញុំនឹងចូលចិត្តតែបទដែលជារបស់លោកស៊ីនស៊ីសាមុតគឺជាបទពីដើមចាសហើយសំរាប់បទដែលមកដល់លូវលូវនឹងគឺសំរាប់ខ្ញុំនឹងគឺដូចគ្មានអារម្មណ៍សោះម៉ងហាសហេហេហេចាសហើយប្រសិនជាខ្ញុំនឹងចូលចិត្តតែបទដែលជារបស់លោកស៊ីនស៊ីសាមុតដែលជាបទពីដើមចាសហើយពេលខ្លះនឹងខ្ញុំក៏បានដេកហើយនឹងបានស្តាប់រហូយដល់ពេលព្រឹកក៏មានដែលសំរាប់ខ្ញុំគឺចឹងហើយប្រសិនជាចង់តែស្តាប់ហើយនឹងចង់តែសប្បាយចឹងហាស៕

ក៖
បាទហើយចឹងអរគុណាច្រើនមែនទែនសំរាប់ថ្ងៃនេះដែលយើងបានពិភាពក្សាហើយចឹង១សំណួរដែលជាសំណួរចុងក្រោយដែលខ្ញុំនឹងចង់សួរទៅកាន់អ្នកមីងថាតើអ្នកមីងមានអ្វីដែលនឹងផ្តែលផ្តាំទៅកាន់កូនចៅរបស់អ្នកមីងហើយនៅពេលដែលពួកគេបានលឺសំលេងរបស់អ្នកមីងអំពីជីវិតលំបាក់ដែលនៅក្នុងជំនាន់ពោលពតរហូតបានមកដល់បច្ចុប្បន្ននេះហើយនៅពេលដែលពួកគាត់បានលឺសំលេងរបស់អ្នកមីងហើយអ្នកមីងនឹងផ្តែលផ្តាំទៅកាន់កូនចៅរបស់អ្នកមីងទាំងនៅក្នុងជំនាន់នេះហើយនឹងជំនាន់ក្រោយក្រោយទៀតដើម្បីអោយពួកគាត់បានកែលំអរហើយនឹងគោរពឪពុកម្តាយអីនឹងថាតើអ្នកមីងមានអ្វីនឹងផ្តែលផ្តាំទៅកាន់កូនចៅរបស់អ្នកមីងដែលរឺទេអ្នកមីង???

ខ៖
ចាសគឺមានហើយខ្ញុំនឹងក៏សូមនឹងផ្តែលផ្តាំទៅកាន់កូនចៅរបស់ខ្ញុំនឹងចាសកូនឯងខំធ្វើហើយនឹងខំរៀនយើងកូនឯងដឹងហើយម្តាយពីបាក់ខ្លាំងណាស់កាលនៅជំនាន់ពោលពតចាសគឺពីបាក់ហូបហើយពីបាក់ចុកនឹងមួយចប់ចឹងហាសហើយម្តាយមានភាពនឿនហត់នឹងការងារហើយនឹងការហូបនឹងក៏មិនបានគ្រាប់គ្រាន់ចាសហើយចឹងមកដល់ជំនាន់នឹងស្រួលរកក៏ស្រួលរកហើយសំរាប់ការហូបចុកនឹងក៏វាមានភាពងាយស្រួលចឹងហាសចឹងហើយសុំអោយកូនឯងនឹងបានខំហើយខ្ញុំនឹងចេះតែផ្តែលផ្តាំទៅកាន់កូនរបស់ខ្ញុំចឹងទៅហាសហើយនឹងរៀនក៏ដោយសុំអោយកូននឹងបានខំរៀនហើយនឹងសិក្សាចាសហើយយើងទោះបីជាយើងមិនបានធ្វើការងារបានធំដំអីនឹងក៏យើងបានទៅធ្វើការងារដែលនៅក្នុងម្លប់អីចឹងទៅហាសហើយទោះជាយើងខ្ញុំគេក៏គេដោយក៏យើងនឹងវាមិនបានទៅហាលថ្ងៃនឹងគេដែលហើយយើងនឹងក៏មិនបានសូវនឿនហត់ដែលចាសហើយសំរាប់ខ្ញុំនឹងចេះតែផ្តែលផ្តាំទៅកាន់កូនហើយនឹងប្រដៅកូនចៅចឹងអោយបានគ្រាប់គ្នាចឹងទៅហាសហើយសំរាប់កូនកូនរបស់ខ្ញុំទាំងអស់ក៏វាបានស្តាប់ខ្ញុំដែលមួយមួយហាសចាសគឺខ្ញុំនឹងនិយាយត្រង់តែម្តងដើម្បីព្រឹងរស់ហើយម្នាក់ម្នាក់មើលមួយកូនទី២របស់ខ្ញុំគាត់បានទៅរស់នៅភ្នំអូរាលនោះហើយគុនរបស់ខ្ញុំនឹង

បានខំហាសដើម្បីប្រពន្ធហើយកូនរបស់ខ្ញុំនឹងខំទាំងយប់ហើយទាំងថ្ងៃគឺកូនរបស់ខ្ញុំនឹងមិនហ៊ានឈប់នោះទេចាសហើយវាខខំប្រឹងហើយសំរាប់ត្រីវាធ្លឹងមានចំនួន៣០០គីឡូរឺក៏៤០០គីឡូរបានគេឡើងមកម្តងចឹងហាសឡើងយកមកលក់ដាក់ឡានដឹកយកមកចឹងហាសពីព្រោះអីនឹងយើងដឹកម៉ូតូចឹងបានតែបន្តិចបន្តិចចឹងក៏កូនរបស់ខ្ញុំនឹងវាដាក់ឡានមកមកដល់ច្បាល់អំពៅចឹងហាសចឹងខ្ញុំនឹងចេះតែប្រដៅកូនចៅរបស់ខ្ញុំហើយខ្ញុំនឹងវានៅពិបាក់ប៉ុន្មាននាក់ទៀតផ្ទះនឹងក៏ជួលគេហើយដីនឹងក៏ជួលគេដែលគឺនឹងក៏ជួលគេរស់នៅដែលសុទ្ធតែនឹងក៏ជួលគេសំបីតែរោងនឹងក៏ជួលគេមកនៅនឹងក៏ជួលគេចាសហើយសំរាប់ខ្ញុំនឹងបានប្របកមុខរបបគឺលក់បបរហើយនឹងបានទៅផ្សារទៅទិញនំដែលបានមកពីផ្សារហាសចាសខ្ញុំបានទិញមួយមុខបន្តិចមុខបន្តិចយកមកលក់ចឹងហាសហើយយើងនឹងសន្សំសន្សំបាន២រឺ៣ពេលចឹងយើងក៏បានសន្សំបានលុយទិញនឹងចំនួន
៧០០ដុល្លាបានទិញដីនឹងបានយើងបានរស់នៅទីកន្លែងនឹងតែម្តងដល់ពេលហើយខ្ញុំនឹងចេះតែបន្តមានមុខរបបចិញ្ចឹមសត្វជ្រូកហើយខ្ញុំនឹងបានជួលដីរបស់គេទៀតចឹងហាសចាសចិញ្ចឹមសត្វជ្រូកសន្សំសន្សំដែលមកពីការចិញ្ចឹមសត្វជ្រូកនឹងហើយកូនរបស់ខ្ញុំនឹងដែលពួកគេនៅលីវដែលបានរស់នៅជាមួយនឹងខ្ញុំមានចំនួន២នាក់នឹងក៏បាននាំកូនរបស់ខ្ញុំនឹងអោយខំរកហើយនឹងខំធ្វើចឹងទៅដែលយើងចិញ្ចឹមសត្វជ្រូកក៏បានលុយបានកាក់ហើយក៏បានធ្វើផ្ទះបានចែកអោយកូនទៅចាសហើយលូវនឹងខ្ញុំបានរស់នៅតែ២នាក់អាពៅទេចឹងហាសហេហេហេចាសគឺរស់តែ២នាក់អាពៅហើយខ្ញុំកំពុងគិតថាស្អែកនឹងចង់ផ្តើមមកលក់បបរនៅកន្លែងនឹងវិញចឹងហាសហេហេហេធ្វើបបរធ្វើអីសំរាប់លក់ដូចថាយើងនឹងនៅទំនេរនឹងវាមិនស្រណុកដូចថាយើងនឹងធ្លាប់រកស៊ីចឹងហាសលក់ដូរចាសហើយនៅពេលដែលខ្ញុំនៅស្រុកចឹងកាល់កូនរបស់ខ្ញុំនឹងនៅតូចតូចអូនហាសចាសគឺខ្ញុំនឹងបានដឹកត្រីម៉ោង១រឺក៏ម៉ោង២អីនឹងគឺខ្ញុំបានឡើងពីផ្ទះស្រុកគឺស្រុកឃ្លាំងហើយយើងគិតមើលស្រុកនឹងគឺជាស្រុកត្រណុបហើយគឺជាស្រុកត្រណុបព្រៃជុំវិញហាសចាសគឺជាព្រៃដែលមានមួយអោបអោបហើយមួយស្វាហើយយើងបានមក២នាក់ម្តាយហើយកូនហើយនៅផ្ទះនឹងគឺធ្វើត្រីដល់ពេលនឹងហើយយើងក៏បានដឹកត្រីមក២នាក់កូនចាសហើយកាល់នឹងមានចោលប្លន់តែយើងចេះតែនឹកឃើញចឹងទៅពីព្រោះយើងនឹងវាអត់មានពីព្រោះអីនឹងប្តីរបស់យើងនឹងគាត់បានស្លាប់ហើយកូនរបស់យើងនឹងពួកវានៅតូចតូចចាសគឺខ្ញុំបានមក២នាក់ម្តាយនឹងកូនទី២របស់ខ្ញុំនឹងមកលក់ត្រីអូនអើយកំសត់ណាស់ចាសម៉ោង១ហើយនឹងម៉ោង២អីនឹងមកហើយពីព្រោះនឹងយើងធ្លឹងត្រីលរហាសធ្លឹងត្រីលរមកមកហើយបានមកដល់ផ្សារចំប៉ាបានបន្តិចចឹងខ្ញុំចាសប្រវត្តរបស់ខ្ញុំខ្ញុំធ្វើហើយខ្ញុំខំប្រឹងរកហ៊ុមកំសត់ណាស់ចិញ្ចឹមកូនហើយទាំងចិញ្ចឹមប្តីនឹងចិញ្ចឹមកូនហើមហាត់ខ្លាំងណាស់៕

ក៖

បាទចឹងអ្នកមីងមានអ្វីដែលផ្តែលផ្តាំទៅកាន់កូនចៅរបស់អ្នកមីងដើម្បីអោយពួកគាត់បានចេះគោរពឪពុកម្តាយហើយអោយគាត់បានចេះខំប្រឹងប្រែងជួយឪពុកម្តាយអីទៀតដែលទេអ្នកមីង???

ខ៖

ចាសសំរាប់ខ្ញុំប្រសិនជាពាក្យផ្តែលផ្តាំខ្ញុំវាមានហូលហែលហើយផ្តែលផ្តាំគ្រាន់តែអោយកូននឹងបានចេះខំរកហើយនឹងចេះគោរពគ្នាហើយនឹងចេះរាប់រកបងប្អូនហើយនឹងចេះស្រលាញ់គ្នាចឹងទៅហាសហើយនឹងចេះគោរពឪពុកម្តាយអីចឹងចាសវាមានពាក្យផ្តែលផ្តាំទៅកាន់កូនរាល់ថ្ងៃនឹងហើយនៅពេលដែលបានស្តាប់លោកទេះស្មារអីចឹងបើលអោយលឺហើយហើយក៏បានបើកអោយស្តាប់ដែលចាសកូនឯងស្តាប់ហើយនឹងយកចិត្តទុក្ខដាក់យើងម្តាយឪពុកយើងចាសសំរាប់ម្តាយហើយនឹងឪពុករបស់ខ្ញុំនឹងគឺខ្ញុំបានគោរពលោកទាំង២នាក់ខ្លាំងណាស់ហើយសំរាប់ខ្ញុំនឹងក៏មិនបានមានពាក្យធំអីដាក់ឪពុកម្តាយរបស់ខ្ញុំដែលហើយដល់មកដល់កូនរបស់ខ្ញុំនឹងគឺថាយើងប្រដៅវាគឺពួកវាមិនសូវជាស្តាប់យើងនោះទេមាននាក់ខ្លះក៏មានពាក្យសំម្តីដាក់មកយើងធំធំចឹងទៅហើយយើងថាមិនបានហេហេហេ៕

ក៖

បាទហើយចឹងពាក្យផ្តែលផ្តាំរបស់អ្នកមីងគ្រាន់តែពួកគាត់នឹងចេះគោរពឪពុកម្តាយហើយចេះរាប់អានហើយនឹងចេះស្រលាញ់បងប្អូនហើយដែលមិនអោយទៅធ្វើអ្វីដែលមិនគប្បីទៅនឹងគ្រួសារនោះទេមែនដែលទេអ្នកមីង???

ខ៖

ចាសគឺមិនចង់នោះទេចាសហើយសំរាប់ខ្ញុំនឹងចេះតែហាមកូនហើយកូនរបស់ខ្ញុំគឺមានប្រុសចំនួន៣នាក់តែម្នាក់ប្រុសច្បងគេនឹងគឺវាមិនអីនោះទេគ្រាន់តែវានឹងខិលខូចតែរឿងស្រីនោះទេហើយសំរាប់អារឿងថ្នាំហើយនឹងជុកអីនឹងគឺថាមិនបាច់ថាភ័យអីនឹងវានោះទេហើយដល់នៅអា២នាក់អ្នកហើយអាពៅនឹងគឺថាវាដាច់ខាតហើយសព្វថ្ងៃនឹងវាខ្លាចតែអាមួយជួរទៅខាងក្រោមនោះទេចាសគឺវាខ្លាចតាមគេចឹងហាសហើយខ្ញុំចេះតែខ្លាចវានឹងបានតាមគេគឺវាជុកតាមគេចឹងហាសហើយសំរាប់ខ្ញុំនឹងចេះតែហាមកូនរាល់ថ្ងៃនឹងគឺចេះតែហាមថាកូនឯងកុំតាមពួកវាហាសប្រយ័ត្នពួកវាហើយនឹងកុំជុកហើយក៏កុំស៊ីតាមពួកវាចឹងទៅហាសចាសខ្លាចហើយទុក្ខកេតរ៏អោយឪពុកម្តាយរបស់យើងហើយនឹងបងប្អូនរបស់យើងពីព្រោះអីនឹងត្រគោលរបស់យើងគឺគ្មាននាក់អីចឹងទេហាសចឹងហើយយើងនឹងចេះតែប្រយ័ត្នហើយខ្ញុំបានលឺខាងសាច់ប្រពន្ធរបស់វានឹងហាសស្រាប់តែបានលឺខាងសាច់ប្រពន្ធរបស់វាគឺត្រូវបានគេចាប់ហើយនៅពេលដែលខ្លួនឯងក៏បានភ័យហើយនឹកឃើញចឹងក៏ភ័យហើយក៏បានទៅមើលកូនខ្លាចវាទៅតាមគេចឹងហាសហើយដល់ដែលខ្ញុំនឹងទៅគឺកូនរបស់ខ្ញុំនឹងគឺកំពុងតែដេកនៅនឹងផ្ទះកូនឯងកុំដើរតាមពួកអស់នឹងហាសកូនហែងមើលគំរូប្អូនរបស់ហែងហាសចាសកូនរបស់ខ្ញុំនឹងអាពៅនឹងគឺអត់ទេហើយពួកម៉ាក់របស់វានឹងហាសថាហែលនឹងឈប់ថ្នាំទៅហើយប្រសិនជាហែងនឹងនៅតែជុកទៀតគឺអញនឹងឈប់រាប់រកហើយមែនគឺកូនរបស់ខ្ញុំគឺឈប់រាប់រកមែនហើយអាណាដែលជុកថ្នាំអីនឹងគឺវាឈប់និយាយរកតែម្តងគឺឈប់រាប់រកតែម្តងចាសពីព្រោះអីនឹងវាមិនចូលចិត្តចាសគឺវាស្អប់វាចាសអត់ភ័យរឿងកូនរបស់ខ្ញុំដល់ពេលចឹងចេះតែណែនាំហើយនឹងប្រដៅកូនចៅកូនប្រសាអីនឹងគេហៅកូនគ្រាប់គ្នាចឹងចឹងខ្ញុំស្រួលរកកូនប្រសារចឹងហាសចាសហើយអោយខំតែរកហើយនឹងខំតែធ្វើទៅចាស៕

ក៖
បាទចឹងអរគុណច្រើនមែនទែនអ្នកមីងចឹងថ្ងៃនឹងខ្ញុំមានតែប៉ុននឹងសំរាប់ការសំភាសន៍ហើយនឹងពិភាក្សាហើយនឹងជជែកលេងជាមួយនឹងអ្នកមីងចឹងថ្ងៃនឹងខ្ញុំមានតែប៉ុនសំរាប់អ្នកមីងចឹងអរគុណច្រើនមែនទែនចឹងអរគុណអ្នកមីងចឹងអរគុណច្រើនណាស់អ្នកមីង៕